# ការសំភាសន៍ជាលើកទី២របស់អ៊ីស្រី ម៉ូវ តាំង

អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា អ្នកដែលត្រូវគេសំភាសន៍ឈ្មោះម៉ូវ តាំង

**ប្រវត្តិសង្ខេបរបស់អ៊ីស្រី ម៉ូវ តាំង**

នៅក្នុងការនេះអ៊ីស្រីម៉ូវតាំងបានរៀបរាប់ពីជីវិតរបស់គាត់ពីភាពលំបាកនៅក្នុងជីវិតអ៊ីបាន សិក្សាតែដោយសារតែអត់រៀនចេះគឺត្រូវបានបញ្ចប់ការសិក្សាហើយ អ៊ីស្រីបានរៀបការមានប្តី ៣នាក់ដោយសារប្តីទី១ស្លាប់នៅជំនាន់ប៉ុលពតហើយកូនស្លាប់ទៀត អ៊ុំចឹងបន្ទាប់ពេល បែកមកគាត់បានយកប្តីមួយទៀតហើយមានកូនច្រើនហើយប្តីទី២បានស្លាប់ ប្តីទី២បានអោយគាត់យកស្វាមីមួយទៀតព្រោះគាត់ថាគាត់លែងបានមានសមត្ថភាពដើម្បីចិញ្ចឹមហើយអោយយកប្តីដើម្បីមើលថែគ្នាទៅ។នៅក្នុងសង្គ្រាមគឺអ៊ីស្រីមានភាពលំបាកសឹងតែគេយកសម្លាប់ចោលហើយគេតែងតែគំរាមគាត់ហើយគាត់បានឃើញគេសម្លាប់មនុស្សហើយគាត់ភ័យណាស់ ហើយមិនអោយពួកប៉ុល ពត ឃើញថាគាត់ឃើញនោះទេហើយគាត់ឡើងញាក់ព្រោះភ័យខ្លាំងបន្ទាប់ពីបែកប៉ុលពតមកអ៊ីបានរកស៊ីមានគ្រួសារហើយរកចិញ្ចឹមកូន ហើយគាត់សព្វថ្ងៃប្រកបរបររាំឆៃយ៉ាំនៅពេលគេអញ្ជើញទៅរាំឬក៏មានបុណ្យទានអីម្តងម្កង។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ីស្រីដែលអោយញ៉ាមសំភាសន៍អំពីជីវប្រវត្តិ របស់អ៊ីជាលើកទី២នាងខ្ញុំឈ្មោះញ៉ែមសុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ី នៅក្នុងថ្ងៃនេះពួកយើងសំភាសន៍នៅក្នុងខែមិនាឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិត នៅក្នុងភូមិព្រៃកហូរខាងលិច ឃុំព្រៃកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា ហើយពួកយើងនិងសួរបន្ថែមទៀតអំពីជីវប្រវត្តិរបស់អ៊ីដែលអ៊ីអត់ទាន់បាននិយាយពេលការសំភាសន៍ជាលើកទី១នោះអ៊ុំចឹងចង់អោយអ៊ីរៀបរាប់ពីជីវិតរបស់អ៊ីថាតើឆ្លងកាត់ រឿងអីគេខ្លះហ្នឹង!! អ៊ុំចឹងអ៊ីសូមប្រាប់ឈ្មោះពេញម្តងទៀត!!

ខៈ ឈ្មោះម៉ូវ តាំង។

កៈ អ៊ុំចឹងអ៊ីសំរាប់ចូលការសិក្សារបស់អ៊ី អ៊ីរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈ អ៊ីអត់ដែលបានរៀនផង រៀនថ្នាក់ទី១០ដែរហ្នឹងតែអត់ចេះ។

កៈ អ៊ុំចឹងពេលមុនទី១០ហ្នឹង គេរាប់បញ្ច្រាស់ហ្នឹងទី២ទី៣ឥឡូវនេះហ្នឹងហី?

ខៈ ចា៎!!

កៈ អ៊ុំចឹងទី១២ថ្នាក់ទី១?

ខៈ ចា៎!!

កៈ ទី១១ថ្នាក់ទី២?ទី១០ថ្នាក់ទី៣អ៊ុំចឹងអ៊ីរៀនបានថ្នាក់ទី៣ដែរ?

ខៈ ចា៎!!

កៈ ពេលថ្នាក់ទី៣ហ្នឹងអ៊ីហ្នឹងមានអ៊ីបានអានអក្សរចេញខ្លះទេ?

ខៈ អត់អានចេះទេ។

កៈ រៀន២ ៣ឆ្នាំហើយម៉េចអត់អានចេញ?

ខៈ អត់រៀនមិនចេះម៉ង!!

កៈ ម៉េចអ៊ុំចឹងវិញ?

ខ៖ បើសរសេរ សរសេរបានបើដល់តែពេលឡើងអានឡើងអានអត់រួច។
ក៖ ចុះឥឡូវនៅតែសរសេរបានទេ?
ខ៖ ឥឡូវលែងបានហើយ។
ក៖ មើលអត់ឃើញម៉ងហេសរសេរលេងកើតម៉ងហេ?
ខ៖ ចាំ!! សរសេអត់កើតទេ ងងឹតភ្នែកផងអីផង។
ក៖ ហ្អំឥឡូវហ្នឹងភ្នែកហ្នឹងមើលព្រិលៗទេហ្នឹងហេ?
ខ៖ ចាំ!!
ក៖ អ៊ុំចឹងអ៊ីពេលដែលអ៊ីរៀនហ្នឹងហាសាលាបឋមសិក្សាណាដែលអ៊ីរៀន?
ខ៖ សាលានៅវត្ត។
ក៖ នៅក្នុងវត្តហេ?
ខ៖ ចាំ!!
ក៖ នៅក្នុងវត្តអីគេវិញ?
ខ៖ វត្តភ្នំចក។
ក៖ នៅណាវិញទៅអ៊ី?
ខ៖ នៅស្រុកហ្នឹង។
ក៖ នៅស្រុកដែលអ៊ីកើតហ្នឹងហេ?
ខ៖ ចាំ!!
ក៖ ចាំ ហើយអ៊ីពេលនៅរៀននៅសាលាហ្នឹងមានពួកម៉ាក់ហ្នឹងនៅសាលាអីអត់?
ខ៖ មានទៅរៀនហូបតែផ្លែគរផ្លែខ្នុរហ្នឹង!! បុកអំបិលទៅ។
ក៖ អាខ្ចិបខ្នុរហ្នឹងអ៊ីហេ?
ខ៖ ចាំ!! ហើយគ្រូលោកហ្នឹង!!ចេះតែមុននឹងចេញមកផ្ទះហ្នឹងសុទ្ធតែបង្ហាត់រាំ។
ក៖ រាំអីគេវិញទៅអ៊ី?
ខ៖ រាំវង់រាក្បាច់មានស៊្មីទះគុរាំហ្នឹង។
ក៖ អ៊ីឥឡូវគេអត់សូវហូបផ្លែគរទេអ៊ីហី?
ខ៖ គេក្មេងៗឥឡូវគេអត់សូវចេះហូបទេ។
ក៖ ចាំ!!ឥឡូវអត់សូវមានគរហូបទៀតហ្នឹងអ៊ីមែនទេ?
(មិត្តភក្តិគាត់)៖ គរហ្នឹងស្លរកកូរទៀតហ្អំ!!!!
ក៖ អ៊ុំចឹងអ៊ីសំរាប់ពួកម៉ាក់របស់អ៊ីគាត់ឈ្មោះអីគេដែរពេលអ៊ីនៅរៀនហ្នឹង
ចាំឈ្មោះគាតទេ?
ខ៖ ចាំតែ២ ៣នាក់ជិតផ្ទះ។
ក៖ ឈ្មោះអីគេវិញអ៊ី?
ខ៖ ឈ្មោះសារ៉ាត់ឈ្មោះសារឹម កាថានកាថែនអ៊ុំចឹង។ក៖ចាំ!!ខ៖ ២ ៣នាក់ហ្នឹង។
ក៖ ឥឡូវពួកម៉ាក់របស់អ៊ីនៅរស់ទាំងអស់គ្នាហើយក៏ខ្លះស្លាប់បាត់ហើយ?
ខ៖ អ្នកខ្លះស្លាប់បាត់ហើយនឹង។បែកគ្នាយូរអស់មក។
ក៖ ឥឡូវគាត់នៅភូមិស្រុកហ្នឹងតើអ៊ីហី?
ខ៖ គាត់នៅភូមិតែខ្លះមានប្តីមានសីបែកទៅនៅតាមប្តីអីអ៊ុំចឹងទៅណាស់។
ក៖ ហ្អំ ភាគច្រើនអ៊ីចូលចិត្តលេងអីគេជាមួយពួកគាត់ជាងគេ?
ខ៖ លេងត្រែស លោតមឹក ផ្ទាត់កៅស៊ូ។
ក៖ ផ្ទាត់កៅស៊ូដែរហេ?
ខ៖ ចាំ!!
ក៖ ចាំ!ភាគច្រើនពេលហ្នឹងល្បែងពេញនិយមភាគច្រើនតែអ៊ុំចឹងអ៊ីណេះ?
ខ៖ ហ្នឹងហើយ។
ក៖ ហ្នឹងហើយអ៊ីតែឥឡូវអត់សូវឃើញក្មេងៗលេងត្រែសទេអ៊ីណេះ?
ខ៖ ឥឡូវអត់សូវលេងទេ ភាគច្រើនក្មេងឥឡូវគេលេងឈូស។
ក៖ ហ្អំ!!ឈូសដាក់លុយអីអញ្ចឹងហ្អំ!!
ខ៖ ចាំ ហើយក្មេងឥឡូវវាចេះលេងល្បែងទៀត។មិនមែនដូចញ៉ុមអីអត់ចេះណា។

កៈ ចាំហ្នឹងហើយ
ជំនាន់មុនបណ្ដុះគំនិតក្មេងអីវ៉ាន់អីមកលេងអីមើលទៅសមរម្យមែន
ទេអ៊ីណោះ?
ខៈ ចាំ!!
កៈ ដល់ពេលសម័យឥឡូវចំលែកៗណាស់ ។
ខៈ ចំលែក!!
កៈ បើសិនជាអ្នកខ្លះមើលតែទូរទស្សន៍អាខ្លះលេងបៀរលេងអីអ៊ីចឹង!!
ខៈ ចាំ!!ហ្នឹង។
កៈ ហើយលេងអីបន្តិចច្រើនតែវ៉ៃគ្នា។
ខៈ មិនមែនដូចយើងពីដើមណា!!
កៈ
អ៊ីចឹងអីសំរាប់ក្ដីស្រម៉ៃរបស់អ៊ីនៅពីក្មេងពេលអ៊ីរៀននៅសាលាអីវ៉ាន់ហ្នឹងហ៎ា!!អ៊ី
មាន
ដែលថាក្ដីស្រម៉ៃចង់ធ្វើអីអត់?
ខៈ អត់មាននឹកឃើញអីទេ ព្រោះអីនឿយពេក បើមើលតែប្អូន។
កៈ ហ៊ុៗ!!
ខៈ ប្អូនច្រើន!!
កៈ ៨នាក់ណោះ!!!!ហើយឡើងលញ្ជះម៉ងអ៊ីណេស?
ខៈ ចាំ!!
កៈ មួយឆ្នាំៗម៉ងអ៊ីហេ?
ខៈ មួយឆ្នាំៗឡើងគ្រដឹក។
កៈ ហើយម៉ែឪទៅណាបានអ៊ីនៅមើល?
ខៈ គាត់ធ្វើស្រែ។
កៈ ហ្ហ៎អ៊ីចឹងអ៊ីរ៉ាប់រងប៉ុន្មានគ្រឿងហ្នឹងទាំងអស់?ខៈ ចាំ!!
កៈ ហើយប្អូនៗរពឹសៗទេអ៊ី?
ខៈ រពឹសរពឹស ពារទាល់តែជើងអូសដីហ្ហ៎!!អត់ហ៊ានដាក់ចេញទេខ្លាចលង់ទឹក។
កៈ ហ្ហ៎នៅហ្នឹងបឹងអីច្រើនអ៊ីហេ?
ខៈ វាអត់បឹងទេ កាលញ៉ុមនៅសិត្បូវាមានអណ្ដូងទឹក។
កៈ ហ្ហ៎!!
ខៈ អ៊ីចឹងខ្លាចប្អូនធ្លាក់អណ្ដូង ចេះតែពារ។
កៈ អាអណ្ដូរលូហ្នឹងមែនអ៊ី?
ខៈ ចាំ!!អណ្ដូរលូធំៗប៉ុនហ្នឹង។
កៈ អាហ្នឹងបើធ្លាក់ទៅដឹងតែអត់មានអីនេះម៉ង គឺវាស្លាប់ម៉ង
ព្រោះអីវាហប់ខ្យល់ហ្ហ៎អ៊ី!!
ខៈ ចាំ!!
កៈ អណ្ដូងហ្នឹងហប់ណាស់!!
ខៈ ចាំ!!
កៈ
ដឹងគ្រាន់តែលឺនិយាយគ្រាន់តែយើងមើលឃើញនឹងភ្នែកហ្នឹងក៏យើងឃើញអត់សូវ
មាន
ខ្យល់ដែរអ៊ីណោះ!!
ខៈ ចាំ គ្រាន់តែអោនចេះទៅឡើងវិលមុខ។
កៈ ចាំ!!តែសម័យឥឡូវគេគ្មានអណ្ដូងមួយហ្នឹងទៀតទេ!!
ខៈ ចាំ!!
កៈ ចាំហើយអ៊ីសំរាប់អើរអ៊ីជាអ្នកឡូកឆៃយ៉ាំមែនទេ?
ខៈ ចាំ!!
កៈ ហ្នឹងហើយ អ៊ីចឹងអ៊ីពេលឡូកឆៃយ៉ាំហ្នឹងអ៊ីរៀនមកពីអ្នកណាគេ?

ខ៖
ញ៉ុមដើរលេងគាត់ឃើញញ៉ុមរាំអញ្ចឹងទៅគាត់ហៅញ៉ុមទៅលេងអញ្ចឹងជាមួយអញ្ចឹង
ទៅណាស់!!
ក៖ ចាំ!!
ខ៖ ដល់ហើយញ៉ុមទៅ ញ៉ុមទៅទៅគាត់អោយតំលៃញ៉ុមថោកជាទីបំផុត។
ក៖ ម៉េចទៅ?
ខ៖ អោយលុយញ៉ុម៥០០០។
ក៖ ចាំ!!
ខ៖ ដល់ឥឡូវឪឯងមិនបាច់អោយលុយញ៉ុម៥០០០ទេញ៉ុមសុំលុយឡូក។
ក៖ ហ៊ឺៗ!!
ខ៖ ញ៉ុមថាញ៉ុមសុំយកលុយឡូកគាត់ថាអត់ទេ ត្រូវបានមកចែកគ្នា។
ក៖ ហ្ហ៎!!
ខ៖ អ៊ីចឹងដល់ញ៉ុមទៅលេងទៅ ញ៉ុមចេះតែល្បីគេមើលអញ្ចឹងទៅគេមកជួលហ្នឹង!!
ក៖ ហ្ហ៎ហើយមានក្រុមភ្លេងរបស់អី?
ខ៖ ចាំ!!
ក៖ ហើយអីម៉េចបានឈប់ឡូកឆៃយ៉ាំហ្នឹងអ៊ីចឹង?
ខ៖ អត់ឈប់ទេនៅតែឡូកអញ្ចឹងគ្រាន់តែមិនសូវលេងដូចមុន។
ក៖ ពេលមុនពេញនិយមណាស់អីណាស់!!
ខ៖ ចាំ!!
ក៖ ចាំ!ហើយឥឡូវអី ពេលមុនញ៉ុមឃើញគ្នាអីមានប៉ុន្មាននាក់ហ្ហ៎ណាស់!!
ខ៖ គាត់ស្លាប់អស់ហើយ ដូចតាដាំអីវ៉ាន់ក៏គាត់ស្លាប់ ហ្ហ៎កូនតាញ៉ុមហ្នឹងក៏ស្លាប់។
ក៖ ចាំ!!
ខ៖ អញ្ចឹងអស់ដៃលេងហាំ!!អញ្ចឹងដើរលេងតែជាមួយគេហ្នឹង។
ក៖ ចាំ!!ហើយអីរៀនអាជំនាញឡូកឆៃយ៉ាំហ្នឹងមកពីអ្នកណាគេវិញ?
ខ៖
រៀនមកពីនេះអើរញ៉ុមដូចថាញ៉ុមដេកអ៊ីចឹងទៅមានដូចថាដូចមានគ្រូមានខ្មោចអីមក
ប្រាប់អីអ៊ីចឹងណាស់!!
ក៖ អីអ៊ីចឹងទៀត អីប្រាប់ញ៉ុមបន្តិចមើលអញ្ចឹងញ៉ុមចង់ដឹងដល់ហើយនេះ!!!
ខ៖
ដល់ពេលញ៉ុមដេកអញ្ចឹងទៅគាតមករាំមករែកដាក់យើងអញ្ចឹងទៅអញ្ចឹងទៅយើងយក
តំរិះតាម ដល់ពេលយើងទៅលេងទៅយើងធ្វើតាមអ្នកមកប្រាប់យើងហ្នឹង។
ក៖ ហ្ហ៎!!
ខ៖ ចាំ!!
ក៖ អញ្ចឹងអីពេលគេយកមកប្រាប់ហ្នឹងភ្នែកស្រស់មែនអី?ហឺក៏ក្នុងយល់សប្តិ?
ខ៖នេះដូចថាយើងដេកអត់ទាន់លក់ទេហ្នឹងមកអោយឃើញម៉ងហើយអ៊ីចឹងគេ
ចេះតែរាំដាក់យើងអញ្ចឹងទៅមើលគេភ្លឺសៗទៅដល់តែមើលហើយពេលយើងទៅ
លេងធ្វើតាមគេអញ្ចឹងទៅ។
ក៖ ហ៊ុឡូយហិ!! ហើយអញ្ចឹងអីខ្លាចទេដល់មកភ្នែកស្រស់ៗអ៊ីចឹង?
ខ៖ អត់ខ្លាចទេ ។
ក៖
ដោយសារដឹងហើយហេ?ខ៖ចាំ!!ក៖និយាយថាមកហ្នឹងមកច្រើនដងឬក៏មកតែម្តងពីរដង?
ខ៖ មកដូចថាមួយយប់អញ្ចឹង ពីរយប់បីយប់អន់ឃើញហើយ !!
ក៖ ហ៊ឺៗ!!ខ៖មកជួនគ្នាបីយប់។

ក៖ វារាល់យប់ឬក៏យូរៗម្តង?

ខ៖ អត់ទេវាម៉ាក្នុងមកហ្នឹងបីយប់ហ្នឹងហើយលែងមកទៅ។

ក៖ ហ្អ៎អ៊ីចឹងលែងមានទៅ?

ខ៖ ចា៎!!

ក៖ ហើយអញ្ចឹងអ៊ីបានចំនេះវិជ្ជាហ្នឹងទៅ?

ខ៖ ចា៎បានដំរិះវិជ្ជាហ្នឹង ដើរលេងឃើញទេគេរៀបសុទ្ធតែព្រះពីសូកកាទេ។

ក៖ ហ៊ុៗ!!អញ្ចឹងសុទ្ធតែរៀបអីអោយអញ្ចឹង?

ខ៖ ចា៎!!

ក៖ បើមិនរៀបអោយម៉េចទៅអ៊ី?

ខ៖ បើមិនរៀបអោយយើងលេងពិបាក។

ក៖ អញ្ចឹងមានអារម្មណ៍អញ្ចឹងម៉ងអ៊ីហេ?

ខ៖ ចា៎!!ដូចថាវាប្រទាំងប្រទះគ្នាហ៎ា!!

ក៖ អ៊ីចឹងអ៊ីថាម៉េចធ្លាប់លេងយីកេទៀតហេ?

ខ៖ ហ្នឹងហើយធ្លាប់ហាត់លេង។

ក៖ អញ្ចឹងម៉េចទៅអ៊ីលេងយីកេហ្នឹង?

ខ៖ យីកេរាំផម្ទុតា ចេញអញ្ចឹង អញ្ចឹង។

ក៖ អ៊ីនៅចាំទាល់តែឥឡូវយេកេហេ?

ខ៖ ចា៎ គ្រូញ៉ុមឈ្មោះតាអ៊ុំយ។

ក៖ ចា៎!!

ខ៖ តែគាត់ស្លាប់បាត់ទៅ។

ក៖ ចា៎!!អ៊ីលេងយីកេតាំងពីអាយុប៉ុន្មានវិញ?

ខ៖ ហ៊ុំអាយុតិចឆ្នាំដែរហ្នឹង៧ ៨ឆ្នាំ។

ក៖ ចា៎តែជំនាញខាងអ៊ីចឹងម៉ងហេ?

ខ៖ ចា៎!!

ក៖ ហើយអ៊ីម៉េចដែរ!! តែអ៊ីយីកេគេអត់មានជួលរាំអីណាអ៊ីហី?

ខ៖ អត់ទេ។

ក៖ តែឆៃយ៉ាំមួយទេ?

ខ៖ ចា៎!!

ក៖ចា៎ញ៉ុមចាំហើយពេលញ៉ុមនៅពីទូចញ៉ុមឃើញអ៊ីឡូកឆៃយ៉ាំនៅតែគ្រប់កន្លែងហ្នឹង!!!

ហើយអ៊ីភាគច្រើនការជួលឆៃយ៉ាំហ្នឹងហ៎ា!!គេជួលទៅពិធីអីគេដែរបានគេរាំឆៃយ៉ាំ?

ខ៖ អើរបុណ្យកឋិន បុណ្យផ្កា ពេលចូលឆ្នាំ នឹងភ្ជុំ។

ក៖ ចា៎ !អញ្ចឹងវាមានតាមរដូវកាលដែរហ្នឹងអញ្ចឹង?

ខ៖ ចា៎!!ក៖អត់មានអីច្រើនដែរហ្នឹង?

ខ៖អត់មានអីច្រើនទេតែបើគេមានស្គាភ្លូមិស្គារអីអញ្ចឹងមានគេជួលក៏បានអញ្ចឹងទៅ បើគេអត់ជួលក៏អត់ទៅ។

ក៖ ចា៎!!ឥឡូវមួយវង់របស់អ៊ីហ្នឹងនៅធ្វើទល់សព្វថ្ងៃ?

ខ៖ ចា៎!!

ក៖ ឥឡូវមានសមាជិកប៉ុន្មាននាក់ដែរត្រូវធ្វើរាំហ្នឹងរបស់អ៊ីហ្នឹង?

ខ៖ បើសិនជាមានគេមកជួលញ៉ុមដើររើសយកដៃ។

ក៖ ហ្អ៎!!

ខ៖ អ្នកគ្នាលេងពីណោះមកហ្នឹង !!

ក៖ ចា៎!!

ខ៖ អញ្ចឹងយកគេយកមកដាក់មក។

ក៖ អ៊ីនៅតែស្គាល់ពួកគាត់រហូតហេ?

ខ៖ ចា៎!!ហើយបើគេណោះគេជួលអ៊ីចឹងគេមករើសពួកញ៉ុមយកទៅ!!

កៈ ហ្នំ!!
ខៈ អញ្ចឹងរើសញ៉ាំមហើយតាហ្នឹងយកទៅ។
កៈ ប្រហែលជាប៉ុន្មានឆ្នាំគេជួលម្តងហាប៉ុន្មានខែគេជួលម្តង ឬក៏ញឹកញាប់ដែរ?
ខៈ
អត់ទេបើក្នុងក្នុងពេលកបិនអ៊ីចឹងវាសុទ្ធជួនថ្ងៃគ្នាណាស់!!ជួនកាលខុសថ្ងៃគ្នាអ
ញ្ចឹង
ទៅជួនកាលជួនថ្ងៃគ្នា។
កៈ ហើយដល់ពេលជួន?
ខៈ ជួនយើងទទួលបានតែមួយដូចថាដូចអូនឯងមកមុនអញ្ចឹងបានទៅណាស់!
កៈ ចា៎!!
ខៈ បើបងមកក្រោយអញ្ចឹងអត់ទៅ!!
កៈ អញ្ចឹងទៅ!
ខៈ ហ្នឹង!!
កៈ អត់ព្រមជៀសថ្ងៃគ្នាបានលុយច្រើន។
ខៈ
ឈៀងលុយមិនឈៀងថ្ងៃអីជួនកាលថ្ងៃតែមួយៗអ៊ីចឹងទៅណាស់!!អ្នកមកជួលហើ
យ
អញ្ចឹងយើងទទួលគេណេសហើយហើយយើងម៉េចទៅណាទៀត!!
កៈ ម៉េចអ៊ីការឡកឆៃយ៉ាំហ្នឹងវាបានតំលៃគួរសមទេអ៊ី ម្តងៗ?
ខៈ បាន៤ ១០០០០០អីដែរហ្នឹងអញ្ចឹង!!
កៈ ហ្នំតែប៉ុណ្ណឹងហើយគ្នា២ ៣នាក់ចែកគ្នាបាន២ ៣០០០០អីហ្នឹងអ៊ីហី?
ខៈ ចា៎!!
(មិត្តភក្តិអ៊ី)៖ ហ៊ុតឡូវម្នាក់១០០០០០ហី?
ខៈ ឥឡូវម្នាក់១០០០០០។មុនម្នាក់បាន២០០០០អីហ្នឹង!!
កៈ ហ្នំតែឥឡូវបានម្នាក់១០០០០០អីហេ?
ខៈ ចា៎!!
កៈ ហើយអ៊ីឥឡូវខានរាំឆៃយ៉ាំប៉ុន្មានខែហើយ?
ខៈ មើលតាំងពេលនេះភ្ជុំមក។
កៈ ហ្នំភាគច្រើនដើររាំតាមវត្តអីអញ្ចឹងទៅអ៊ីណេះ?
ខៈ ចា៎!!
កៈ ចា៎!!អ៊ីស្រលាញ់មួយហ្នឹងទេ?ការងារគឺត្រូវតែស្រលាញ់ហើយហេ?
ខៈ ការងារ តែប៉ុណ្ណឹងចាស់ប៉ុណ្ណឹងហើយគេថាទៀត!!
កៈ ថាម៉េច?
ខៈ
នៅតែលេងកើត!!ញ៉ាំមថាលេងទាល់តែទៅជាផេះ។អើរលេងកើតចេះតែលេងទៅ។
កៈ ពេលហ្នឹងលេងតាមភូមិ។
ខៈហ្នឹងហើយដើរលេងតាមភូមិហើយអត់មានអ្នកណាជួលទេ
ហ្នឹងចូលឆ្នាំយើងដើរលេងអញ្ចឹងម៉ងទៅ!!!
(មិត្តភក្តិអ៊ី)៖ បានលុយយកទៅចែកគ្នាចាយទៅ!!!
កៈហ្នឹងហើយអញ្ចឹងចេះតែប្រមូលគ្នាមកហើយដើរលេងជាមួយគ្នាទៅ?ខៈចា៎!!កៈ
ហើយបានបច្ច័យមក!!
ខៈ ចែកគ្នាទៅ។
កៈ ចែកគ្នាអញ្ចឹងទៅ!! ហើយមានដាក់អោយវត្តអីទេអ៊ី?
ខៈ អត់ទេ។
កៈ គ្រាន់តែរបៀបថាជាសេរីសួស្តីទៅអ៊ីណេះ?
ខៈ ចា៎!!

កៈ
អ៊ីអត្ថន័យនៃការលេងឆៃយ៉ាំហ្នឹងមានអត្ថន័យម៉េចដែរបានភាគច្រើនជនជាតិខ្មែរយើង
មានបុណ្យអីវ៉ាន់គេធ្វើបុណ្យមួយហ្នឹង អ៊ីដឹងទេ?
ខៈ ហ្នឹងដូចថាគេធ្វើបុណ្យកុំអោស្ងាត់វាកក្រឹកកក្រែងអញ្ចឹងទៅវាសប្បាយ។
កៈ ហ៊ឺៗ!!គ្រាន់តែជាការសប្បាយរីករាយតែប៉ុណ្ណឹងទេអ៊ីហេ?
ខៈ ចាំ!!!
កៈ អត់មានអីត្រូវពិបាកអត់មានអីត្រូវនេះទេ!!!
ខៈ ចាំ!!
កៈហ្នឹងហើយអញ្ចឹងអ៊ីចូលដល់ជីវិតគ្រួសារវិញម្តង
អ៊ីរៀបការជាមួយប្តីដំបូងប្តីឈ្មោះអីគេដែរ?
ខៈ ឈ្មោះតាទូច។
កៈ ឥឡូវគាត់ស្លាប់ហើយមែនទេ?
ខៈ គាត់ស្លាប់ហើយ។
កៈ គាត់ស្លាប់មូលហេតុអីគេដែរ?
ខៈ គាត់ឈឺ។
កៈ ចាំ!!តាទូចហ្នឹងគាត់ខ្ពស់ធំហ្នឹងមែន?
ខៈ ទាប។
កៈ ទាបទេហេ!!តែដល់ពេលបានប្តីក្រោយមកហ្នឹងតារៀងធំមែន?
ខៈ ចាំ!!
កៈ ហ្ហ៎ស្គាល់ហើយតារៀងខ្ពស់ប្តីគាត់ក្រោយ។
(មិត្តភក្តិគាត់)ៈតាទូចកាលហ្នឹងអញទៅដេកពេទ្យអាផលដូចគាត់ទៅដេកពេទ្យដែរ
ដេកពេទ្យកូនដែរតាទូចពេលហ្នឹងស្អាតសាច់ឈាមគាត់ស្អាតស្លៀកពាក់ស្អាតបាតហើយមើលទៅសម មួយថ្ងៃៗដដែកតែគ្នា។
កៈ ឈ្មោះអីគេទូចវិញ អ៊ីត្រកូល?
ខៈ មិនដឹងស្អីគេផង!!ហ៊ឺ អ៊ុល។
កៈ អ៊ុល!! អ៊ុល ទូច?
ខៈ អ៊ុល ទូច ចាំ!!!
កៈ ចាំ ពេលគាត់ស្លាប់ហ្នឹងគាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ៊ី?
ខៈ មិនដឹងប៉ុន្មានឆ្នាំហើយ។
(មិត្តភក្តិគាត់)ៈ យូរឆ្នាំហើយតាទូច។
កៈ ពេលគាត់ស្លាប់អាយុប៉ុន្មានដែរអ៊ី?
ខៈ អើរអាយុប៉ុន្មានទេ ដូច៥៧។
(មិត្តភក្តិគាត់)ៈ ហេតាទូចអាយុច្រើនដែរកាលស្លាប់?
ខៈ ចាំ!!!
កៈ ហើយថីបានស្លាប់មិញ?
ខៈ គាត់ឈឺហើមឈឺហើមនោះ ផឹកហើយអញ្ចឹងហ្ហ៎!!
កៈ ហ្ហ៎ដោយសារផឹកស្រាហ្នឹងបានស្លាប់ហ្នឹង!!
ខៈ ចាំ!!
កៈ បើអត់ផឹកអត់អី !! គាត់អ្នកឡុកឆៃយ៉ាំដែរ?
ខៈ គាត់លេងនៅពេលយើងជាស្នារឹមទេ គាត់រ៉ៃឆៃយ៉ាំ។
កៈ ហ្ហ៎គាត់ទះអាស្គរហ្នឹងហី?
ខៈ ចាំ!!ទះអាស្គរហ្នឹង។
កៈ អ៊ីអាស្គរហ្នឹងទៅរកទិញនៅណាទៅអ៊ី?
ខៈ ទិញគាត់ទិញរបស់តាគាត់ទិញតាំងពីខាងលិចភ្នំតាម៉ៅមក!!
កៈ គេមានអ្នកធ្វើ!! គេធ្វើពីដើមអីគេវិញអ៊ី?

ខៈ គេធ្វើ គេធ្វើពីដើមខ្ទុរយើងហ្នឹង!!
កៈ ហ្ន៎ទះលាន់ខ្លាំងណាស់អាហ្នឹង!!
ខៈ ហើយគេអាស្បែកលើហ្នឹងស្បែកគោយើងហ្នឹង។
កៈ ហ្ន៎បិទទៅ !!ហើយមានអីគេអាមួយកំប៉ុកក្រមួនអីអីអាហ្នឹង?
ខៈ អាហ្នឹងបាយហើយនឹងផេះអំបិលបិត។
កៈ ម៉េចបានគេដាក់អាហ្នឹងធ្វើអី?
ខៈ បិតអាហ្នឹងដាក់ទៅវាលឺ។
កៈ វាទៅអញ្ចឹងវិញ?
ខៈ ចា៎!!
កៈ បើអត់ដាក់អាហ្នឹងវាអត់ឮទេអ៊ីចឹង?
ខៈ អត់លឺទេ។
កៈ ហ៊ីអាហ្នឹងជួយដែរ!!
ខៈ ចា៎!!
កៈ ញ៉ុមឃើញអាហ្នឹងខ្ចើមអើយខ្ចើម!!
ខៈ បាយយើងហើយផេះហ្នឹង ។
កៈ ចា៎!!បាយយើងធម្មតាហ្នឹងហិអី?
ខៈ ចា៎!!
កៈ
ហើយប្ដីហ្នឹងអីគាត់អើរពេលអីរៀបការជាមួយគាត់ហ្នឹងពេលមុនសង្គ្រាមឬក៏បែកសង្គ្រាម
មកហើយ?
ខៈ នេះជំនាន់៧៩(១៩៧៩)នេះ។
កៈ ការនៅក្នុងជំនាន់បែកហើយមកហី?
ខៈ ចា៎ បែកហើយ។
កៈ
ហើយពេលហ្នឹងស្រលាញ់គ្នារៀបការហ្នឹងស្រលាញ់គ្នាចិត្តឯងឬក៏មានម៉ែឪរៀបចំទុក
ដាក់អោយ?
ខៈ អើរម្ដាយមីងមកស្ដី។
កៈ ហ្ន៎ធ្លាប់ស្គាល់គាទូចពីមុនទេ?
ខៈ ចា?
កៈ ធ្លាប់ស្គាល់ប្ដីពីមុនរៀបការអត់?
ខៈ ស្គាល់ធ្លាប់ទៅច្រូតស្រូវពីមុនទាំងអស់គ្នា។
កៈ អ្នកស្រុកនៅហ្នឹងដែរទេ?
ខៈ នេះនៅនឹងព្រែកហូរហ្នឹង!!
កៈ អញ្ចឹងប្ដីអ្នកស្រុកមកពីព្រែកហូរនេះទេ?
ខៈ ចា៎!!
កៈ ហើយអីមកពីកន្ទួត សៀមរាបកន្ទួតនោះ!!
ខៈ ចា៎ !! ញ៉ុមមកនៅព្រែកហូរហ្នឹងដែរ។
កៈ
ចា៎ហ្នឹងហើយអ៊ីចឹងអីពេលប្ដីអីពេលចូលរការស្ដីដណ្ដឹងហ្នឹងគាត់មានអោយជំនូនថ្លៃ
ជំនូនថ្លៃអីអញ្ចឹងទេ?
ខៈ មានណាកាលពី៧៩(១៩៧៩)អត់មានអីទេ ការនោះ ការអង្ករ
ចងដៃអង្ករហ្នឹង។
កៈ ហើយអីម៉េចបានក្រយកប្ដីម្លេះបងម៉ែញ៉ុមទៀតណោះ?
ខៈ ហ៊ីញ៉ុមមានប្ដីរួមមួយសារហើយហ្នឹង!!

កៈ ហ្ហ៎អ៊ុចឹងមុនតាទូចមានប្តីហើយទៀត?ខៈចា៎!!កៈប្តីមុនឈ្មោះអីគេវិញ?
ខៈ ឈ្មោះអួន។
កៈ ហើយម៉េចក៏!!គាត់ស្លាប់អីហេ?
ខៈ គាត់ស្លាប់ជំនាន់ប៉ុល ពត។
កៈ ហ្ហ៎ហើយពេលហ្នឹងរៀបការជាមួយតាអួនហ្នឹងមានកូនអត់?
ខៈ មានកូនមួយ។
កៈ ឥឡូវកូននៅរស់តើហី?
ខៈ កូនស្លាប់បាត់ហើយ។
កៈ ស្លាប់នៅក្នុងជំនាន់ប៉ុល ពតហ្នឹងដែរអត់?
ខៈ ចា៎!!ឪវាស្លាប់បានបីថ្ងៃកូនស្លាប់ដែរ!!
កៈ មូលហេតុបានគាត់ស្លាប់?
ខៈ ស្លាប់អត់បាយ។
កៈ ហ៊ុដោយសារអត់បាយ!!
ខៈ ចា៎!!
កៈ មិនមែនគេយកទៅសម្លាប់ចោលណាហី?
ខៈ អត់បាយ!! អត់ទេ!!
កៈ ចុះតាស្លាប់ដោយសារអត់បាយដែរឬក៏ម៉េច?
ខៈ តា?
កៈ ប្តីហ៎ា?
ខៈ ប្តីញ៉ុមតាអួនហ្នឹងហី?
កៈ ចា៎!!
ខៈ គាត់ស្លាប់នឹងអត់បាយហ្នឹង!!
កៈ មិនមែនស្លាប់ដោយសារគេសម្លាប់ចោលហ្នឹងទេហី?
ខៈ ចា៎!!អត់ទេ!!
កៈ ចា៎ ហើយសម័យអាពតអីនៅឯណាវិញ?
ខៈ នៅស្អិតពោធិ៍សាត់។
កៈ សុទ្ធកន្លែងតែ ឮគេនិយាយថាកន្លែងហ្នឹងសម្លាប់សាហាវណាស់អីហី?
ខៈ ចា៎!!ពួកបូព៌ាសម្លាប់ទាំងពូជទាំងពូជ។
(មិត្តភក្តិគាត់)ៈបងញ៉ុមហ្នឹងមួយបងតាំងហ៎ាបងញ៉ុមធ្វើគ្រូអភិវឌ្ឍនៅហ្នឹងស្លាប់បាត់កំលោះបាត់នៅពោធិ៍ហ្នឹងមុនគេជំលៀសទៅលៀចសម្លាប់រុងគៀលម៉ង!!
កៈ
ហើយអីឥឡូវនិយាយពីប្តីដើមតាទូចសិនពេលគាត់រៀបចំជាមួយគាត់ហ្នឹងអីរៀបជំនាន់
ប៉ុល ពតឬក៏ក្នុងប៉ុល ពត?
ខៈ ជំនាន់លន់ នល់។
កៈ លន់ នល់ហេ?
ខៈ ចា៎!!
កៈ គាត់ធ្វើអីគេដែរ?
ខៈ គាត់ធ្វើទាហាន។
កៈ ទាហានដែរ?
ខៈ ចា៎!!
កៈ តែបានចូលមកក្នុងនេះហើយបានស្លាប់ទៅ??
ខៈ ចា៎!!បានមកស្លាប់នៅក្នុងជំនាន់ប៉ុល ពតហ្នឹង!
កៈ ចា៎ហើយដល់ពេលបែកជំនាន់ប៉ុលពតហ្នឹងបានយកប្តីតាទូចទៀត?
ខៈ ចា៎!!
កៈ ហើយតាទូចស្លាប់ទៅ អីមានយកប្តីទៀតទេ?
ខៈ យកតើ!!តាឆៃយុំហ្នឹង។

កៈ តាឆៃយុំហ្នឹងហេ?
ខៈ ចា៎!!
កៈ តែបីនាក់ហ្នឹងតើហី?
ខៈ ចា៎!!
កៈ ឥឡូវតាឆៃយុំ គាត់ឈ្មោះអីគេតានី ហាមិនមែនទេ!!
ខៈ អីគេ!! ដោក សំអុន។
កៈ ចា៎!!ឥឡូវគាត់ស្លាប់ដែរ?
ខៈ នៅ។
កៈ ឥឡូវនៅមានស្វាមីរាល់ថ្ងៃហ្នឹងហី?
ខៈ ចា៎!!
កៈ ហ្ហ៎អ៊ីចឹងរាល់ថ្ងៃគាត់រស់នៅជាមួយគ្នាអ៊ីចឹងទេហេ?
ខៈ គាត់នៅជាមួយកូនញ៉ុមមកមើលចៅនៅនេះ។
កៈ
ហ្ហ៎នៅមានស្វាមីដែរញ៉ុមស្មានតែមេម៉ាយ!!ចា៎អ៊ីចឹងអ៊ីសំរាប់ជាមួយប្តីដំបូងប្តីទី១មានកូន
តែម្នាក់ទេហេ?
ខៈ ចា៎!!
កៈ ក៏ស្លាប់ទៅ កូនក៏ស្លាប់ប្តីក៏ស្លាប់ទៅ?
ខៈ ស្លាប់ទៅ។
កៈ ម៉េចដែរអ៊ីអារម្មណ៍ពេលហ្នឹង?
ខៈ ពេលហ្នឹងអារម្មណ៍អានិតកូនអានិតប្តីដែលស្លាប់អត់មានអីហូប។
កៈ ហ៊ីពិបាក!!ហើយចុះទី២ តាទូចមានកូនជាមួយគាត់ប៉ុន្មាននាក់?
ខៈ ហ៊ីមានកូនជាមួយតាទូចច្រើននាក់ដែរហ្នឹង!!
កៈ ប៉ុន្មាននាក់ទៅ?
ខៈ ហ៊ីចង់ភ្លេចទៀតហ៎ា!!!
កៈ ចង់ភ្លេចឈ្មោះកូនអ៊ីហេ?
ខៈ ចា៎!!មើលអាទី១មើលនៅកងទ័ពឈ្មោះសុខជឿនតុប។
កៈ ចា៎!!
ខៈ ឈ្មោះចិន្តា រាប់តែរស់ៗទេ រាប់អាមួយជឿន មីមួយចិន្តា មីចាន់ឌី ៣ហើយមួយទៀតចាន់ទូ ៤នៅតែ៤នាក់ហ្នឹង។
កៈ ចា៎អញ្ចឹងដល់ពេលក្រោយមកតាប្តីក្រោយមក?
ខៈ អត់មានកូនផង។
កៈ ហ្ហ៎គ្រាន់តែបានមើលថែគ្នាអញ្ចឹងទៅ?
ខៈ ចា៎!!
កៈ គាត់មកលេងផ្ទះអីវ៉ាន់?
ខៈ មកតើ!!លុយកាក់គាត់ផ្តល់អោយតើ!!
កៈ ចេះបានមើលថែទាំគ្នាអញ្ចឹងទៅ!!
ខៈ
ចា៎ដូចថាជួនកាលញ៉ុមអត់អញ្ចឹងទៅញ៉ុមទៅឪញ៉ុមអត់មានលុយទិញអង្ករអោយចៅ
ហូបទេ ទិញអង្ករអោយកន្លះបេអញ្ចឹងមកអោយលុយមក៥០០០០។
កៈ គាត់នៅឯណាវិញឥឡូវហ្នឹង?
ខៈ នៅមាត់ស្ទឹង។
កៈ ហ្ហ៎នៅជិតនេះដែរហ្នឹងហេ?
ខៈ ចា៎!!
កៈ អញ្ចឹងដើរទៅរកទៅ។
ខៈ នៅក្រោយវត្តហ្នឹង។

កៈ
ចាំហ្នឹងហើយ!!អញ្ជឹងអ៊ីភាគច្រើនស្វាមីស្លាប់បានអ៊ីមានស្វាមីក្រោយទៀតអញ្ចឹង
ទៅ?
ខៈ ចាំ!!
កៈ
ចាំ!!អ៊ីស្រលាញ់គ្នាជាមួយតាប្តីដំបូងចាប់ផ្តើមពីពេលណាមកឬក៏ស្រលាញ់គ្នាគេចូលស្តី
ដណ្តឹងទេ?
ខៈ គេចូលស្តី!!
កៈ ហ្នំជំនាន់លន់ នល់ហ្នឹង?
ខៈ ចាំ!!
កៈ ចាំហើយប្តីជាទាហានម៉េចដែរអ៊ី?
ខៈ ជាទាហានមានអី បើកប្រាក់ខែយកមកអោយយើងអ៊ីចឹងទៅ!!
កៈ ចាំ!!ស្រលាញ់អ៊ីណាស់ប្តីដំបូង?
ខៈ ចាំ!!
កៈ ប្តីទាំងបីនាក់ហ្នឹងមួយណាដែលស្រលាញ់អ៊ីជាងគេ?
ខៈ ស្រលាញ់ដូចតែគ្នា។
កៈ ហ្នំ !! ស្រលាញ់អ៊ីសុទ្ធតែស្រលាញ់ម៉ងហេ?
ខៈ ចាំ!!តាក្រោយនេះក៏អ៊ីចឹងដែរនេះ!!
កៈ ហើយម៉េចបានជួបតាក្រោយ?
ខៈ ពេលតាទួចនេះនោះ!!
(មិត្តភក្តិគាត់)ៈស្លាប់ហេ?
ខៈ អត់ទាន់ស្លាប់ទេឈឺដើរអត់រួចហ្នំ!!
កៈ ហ្នំ!!
ខៈហើយញ៉ុមមកពីលេងឆៃយ៉ាំជាមួយតាវិញលើកញ៉ុមអោយតាហ្នឹង
ដល់ពេលហើយញ៉ុមបន្ទោសគាត់ថាម៉េចឯងលើកអញអោយគេអញ្ចឹង??ថាអញចិញ្ចឹមឯងលែងកើតអញ្ចឹងគាត់បន្ទុកបន្ទាក់លើតាហ្នឹងថាឪឯងយកតាំងចុះថៃរក្សាគ្នាទៅខ្ញុំរកស៊ីចិញ្ចឹមគេលែងកើតហើយ។
(មិត្តភក្តិគាត់)ៈ បងអើយនិយាយអ៊ីចឹងព្រឺសម្បុរដល់ហើយនេះ!!!
ខៈ ហ្នឹង!!!! ហើយក៏គាត់ប្រាប់ថាអោយមើលចិញ្ចឹមគ្នាទៅ គាត់អត់ខឹងទេ។
កៈ តែពេលហ្នឹងដល់ពេលមានតាក្រោយតាទួចអត់ទាន់ស្លាប់ទេ?
ខៈ ចាំនៅ។
កៈ
ហើយដល់ពេលបានប៉ុន្មានឆ្នាំហើយបានតាទួចស្លាប់ពេលនៅជាមួយតាក្រោយ?
ខៈ ញ៉ុមបានតាក្រោយមិនដឹងបានប៉ុន្មានខែផងគាត់ឈឺស្លាប់។
កៈ ហ្នំ!!
ខៈ ញ៉ុមយកទៅមើលទៅអីដែរហ្នឹង។
កៈ គាត់ទឹមតែស្លាប់ដែរទេអ៊ីហេ?
ខៈ ហើយតាហ្នឹងគាត់រែកទឹករែកអីអោយជួយមុជជួយអីអញ្ចឹងទៅណាស់។
កៈ អោយជួយមើលថែប្រពន្ធអ៊ីចឹងទៅ!!
ខៈ ចាំ!!
កៈចាំ!!ឥឡូវនិយាយពីជំនាន់ប៉ុលពតវិញតើជីវិតរបស់អ៊ីនៅក្នុងជំនាន់ប៉ុលពត!!ឥឡូវឈប់សិននិយាយពីពេលទឹមតែកើតមកដឹងក្តីបន្តិចមកនៅជំនាន់សម្តេចមែនទេអ៊ី?ខៈ ចាំ!!
កៈ ហើយម៉េចដែរសប្បាយចិត្តអីទេ?
ខៈ វា នៅពីក្មេងអត់សូវដឹងថាពិបាកអីដែរ។
កៈ ពេលហ្នឹងស្រុកទេសអីសប្បាយអ៊ីហី?

ខ៖ ចា៎!!
ក៖ អត់មានសង្គ្រាមអីទេអ៊ីណោះ?
ខ៖ ចា៎!!
ក៖
អ៊ុំចឹងអ៊ីឥឡូវនិយាយពីជំនាន់លន់នល់តើជីវិតរបស់អ៊ីជួបរឿងអីគេខ្លះអ៊ីអាចនិ
យាយពី
ជំនាន់ លន់ នល់ ហា!!
ខ៖ ជំនាន់លន់ នល់ ជួបឧបសគ្គគ្រាប់បែកគ្រាប់ផ្លោង គេចគ្រាប់ជិតងាប់ហើយ
ដល់មកប៉ុល
ពតរំដោះទៀតគេចគ្រាប់ដាច់មកជាណានឹងដាច់ស្មាទៀតហិ!!គេចអ៊ុំចឹងទៅគេ
ជំលៀសទៅនៅក្រោមហ្នំនៅកោះធំកោះអីនេះហ្នឹងចេះតែដើរទៅនៅតាមផ្លូវហ្នឹង!
!ដល់ទៅដល់ភូមិហ្នឹងគេក៏ទទួលនៅ ទទួលនៅក៏នៅនឹងគេ
ដល់ពេលគេចេះតែសួរយើងធ្វើទាហានហីក៏មួយអីអញ្ចឹង
ដល់ហើយពុកញ៉ុមគាត់ខ្លាចដល់គាត់ខ្លាចគាត់សុំគេចេញមកចេញមកគេអ្នកស្រុ
កគេថាកុំខ្លាចអី
ពុកញ៉ុមអត់ហ៊ានទេខ្លាចគេសម្លាប់ចោលនោះ!!ក៏គាត់ចេញមកពោធិ៍សាត់មក ។
ក៖ ដើរមកមកអ៊ីហី?
ខ៖
ហ្នឹងហើយដើរមកមកកន្លែងស្អីគេកន្លែងនៅរ៉ាំរទេះភ្លើងនោះរទេះភ្លើងហ្នឹងគេ
អោយ
ដេកនៅផ្លូវហ្នឹងប៉ុន្មានថ្ងៃហ្នំ!!បានបានរទេះភ្លើងបានដឹកទៅយកទៅចែកទៅតា
មភូមិ។
(មិត្តភក្តិគាត់)៖បងឯងជិះរទេះភ្លើងហ្នឹងដូចញ៉ុមហើយហិ!!ញ៉ុមជិះរទេះភ្លើងទៅ
ពោធិ៍សាត់ដែរ!
ខ៖ នឹងជិះរទេះភ្លើងហ្នឹង អត់មានបាយមានទឹកអីទេនំប៉័ងហូបលើរទេះភ្លើង ។
ក៖ គេអោយហូបហេ?
ខ៖ ចា៎!!
ក៖ អ៊ុំចឹងពេលហ្នឹងអត់ទាន់អាក្រក់នៅឡើយទេអ៊ីហេ?
ខ៖ នៅ នៅឡើយទេ ពេលគេជំលៀសយើង។
ក៖ ហ្ន៎ អ៊ុំចឹងដល់ពេលដំបូងអត់អីទេ ដល់ពេលយូរទៅខ្លាំងទៅខ្លាំងទៅអ៊ីហេ?
ខ៖ ចា៎!!
ក៖
អ៊ុំចឹងអ៊ីឥឡូវដាកមកជំនាន់លន់នល់បន្តិចទៀតសិនពេលហ្នឹងអ៊ីមានជីកត្រង់
សេអីការ
ពារគ្រាប់ពីពេលហ្នឹងអត់?
ខ៖
ជីកជីកត្រង់សេក្បែរផ្ទះអញ្ចឹងមានឈើអីធំៗអីអញ្ចឹងទៅដាក់ក្រាលអីអញ្ចឹងទៅក
ប់ដីពី
លើទៅ។
ក៖ ហើយត្រង់សេហ្នឹងជីកចូលទៅក្រោមជ្រៅទេអ៊ី?
ខ៖ ជ្រៅដែរហ្នឹងល្មមតែយើងសំរានបាន។
ក៖ ចា៎!!
ខ៖
តែគ្រាន់តែថាវាចូលសំរានមិនបានទេវាហប់ចូលបានមួយសន្ទុះៗអោយតែស្ងាត់
គ្រាប់
ផ្លោងហ្នឹង!!
ក៖ ម៉េចដែរអ៊ីដើត និយាយទៅវាឡើងមករហូតម៉ងហេ ?

ខៈ ចាំ!!
កៈ គ្រាប់អាអីគេ?
ខៈ គ្រាប់ផ្លោងហ្នឹង។
កៈ ម៉េចទៅអ៊ី?
ខៈ ដូចឮរើត ឆ្ងាយពីណោះមក វិត វិតៗៗៗ ធ្លាក់ក្តែង។
កៈ អ៊ុំចឹងពេលមុនទំលាក់ហ្នឹងសុទ្ធតែអោយសញ្ញាដែរ?
ខៈ
ចាំ!!ស្តាប់ឮបានដែរតើខ្យល់ឮមកអ៊ីចឹងមកឮផុចអញ្ជឹងមក!!មកហើយមករាក់ៗៗៗៗៗៗ
មកហើយហើយយើងឮហើយចូលទៅផ្លុចៗៗៗទៅ
កៈ តែបើទំលាក់ចំត្រង់សេហ្នឹងក៏!!
ខៈ បើចំទៅស្លាប់អស់ទៅ!!
(មិត្តភក្តិគាត់)៖ មានគន្ធា មានមានចំមួយត្រង់សេហ្នឹងងាប់ទាំងអស់។
ខៈ ងាប់ទាំងអស់ទៅ។
កៈ តែភូមិដែលអ៊ីនៅហ្នឹងអត់មានអ្នកណាធ្លាក់ចំនឹងដែរ?
ខៈ អត់ដែរ។
កៈ ហេងហើយអ៊ុំចឹង!!
ខៈ ចាំ!!
កៈ អ៊ុំចឹងអ៊ីពេលនៅលន់ នល់ហ្នឹងអ៊ីនៅភូមិណាវិញ?
ខៈ ញ៉ុមនៅនេះហ្នឹង នៅតាខ្មៅហ្នឹង។
កៈ មកតាខ្មៅនេះវិញហេ?
ខៈ ចាំ!!ស្អាង ព្រែកតូច សិត្បូ ដើរតែនៅហ្នឹង!!
កៈ
ហ្នុំអ៊ីចឹងដោយសារតែការទំលាក់គ្រាប់ហ្នឹងត្រូវធ្វើអោយយើងដើរនៅពីកន្លែងមួយទៅ
កន្លែងមួយ?
ខៈ ចាំ!!
កៈ ហើយម៉េចពេលហ្នឹងធ្លាយទៅដល់ភ្នំពេញអីអត់អ៊ី?
ខៈ ភ្នំពេញអីអត់បានទៅទេ!!
កៈ តែគេថាដូចនៅភ្នំពេញគេថាដូចអត់សូវអីទេអ៊ីហី?
ខៈចាំ!!!ញ៉ុមអត់ដែលទៅដល់ហ្នឹងទេទោះបីថាអាពតជំលៀសទៅក៏ញ៉ុមអត់ដែលបានទៅ
ដល់ហ្នឹងទៅភ្នំពេញដែរ!!ទៅទៅក្រោមហ្នឹងម៉ង!!
កៈចាំ!!អ៊ីចឹងអ៊ីពេលបែកពីលន់នល់លែងឮគ្រាប់អីម៉េចបានប៉ុន្មានខែបានចូលដល់ប៉ុល ពត?មកវិញម្តងទៀត??
ខៈនេះផ្លោងយូរៗទៅទាហានអីកបាំល់ហោះទំលាក់លើងាប់អីអស់ទៅ
ងាប់ហាំ!!ងាប់រុងគែសរគៀលគ្រាន់តែម៉ែអើយញ៉ុមទៅហើយ
គ្រាន់តែទៅដល់ណោះងាប់បាត់ ដឹកខ្មោចមកវិញ ដល់នេះបានប៉ុន្មានទេ
បែកដេញអាគេចូលមកហ្នឹង។
កៈ អ៊ីពេលជំនាន់លន់ នល់ ហ្នឹងទំលាក់គ្រាប់រាល់ថ្ងៃទេ?
ខៈ វាមិនរាល់ថ្ងៃពេកទេ ដូចថា២ ៣ថ្ងៃឮម្តងអ៊ុំចឹងទៅណាស់
ទំរាំតែយើងភ្លេចត្រចៀកហាំ!!
កៈ អ៊ីលឺគ្រាប់បែកហ្នឹង២ ៣ថ្ងៃហ្នឹងតែម្តងទេ?ហើយទំលាក់រហូត
ឬក៏តែម្តងហ្នឹងហើយ?
ខៈ តែម្តងហ្នឹង តែបួនដប់គ្រាប់ជីងជីងៗគ្រាប់តែកន្លែងហ្នឹង!!
កៈ ហើយទៅអញ្ជឹង?
ខៈ ហ្នឹងហើយ។

កៈ លែងមានទៀតហើយ?
ខៈ ចា៎!!
កៈ ភាគច្រើនវាទំលាក់ទំលាក់ម៉ោងប៉ុន្មាន?
ខៈ ទំលាក់ពេលល្ងាច។
កៈ ទៀងទៀត?
ខៈ ហ្នឹងហើយ។
កៈ ភាគច្រើនពេលល្ងាចគឺមានហើយ?
ខៈ ចា៎!!
កៈ ពីបីថ្ងៃ!!
ខៈចុះមីអូនឯងមើលរណ្តៅអាបេនេះរណ្តៅនេះ សុទ្ធតែកន្លែងរណ្តៅមានស្រះ។
កៈ អូយ!!
ខៈ កាលពី៧៩(១៩៧៩)ញុំមដើរបាចត្រីប៉ា!!
កៈ ចា៎!!
ខៈ លលាក្បាលប៉ុនៗណាណីហ្ន៎!!
កៈ អូយ!!អ៊ីចឹងសុទ្ធតែមួយគ្រាប់មួយគ្រាប់សុទ្ធតែខ្ទេចខ្ទីអស់ម៉ងអី៎ហេ?
ខៈ ចា៎!!ខូងដីប៉ុនៗស្រះ!!
កៈ អ៊ីចឹងអី៎ដល់ពេលចូលដល់ជំនាន់ប៉ុល ពតវិញម្តង
រាល់ថ្ងៃដំបូងនៅក្នុងជំនាន់ប៉ុល ពតហ៎ា វាម៉េចទៅអី៎បានដឹងថាវាជាជំនាន់ប៉ុល ពតអី៎វ៉ាន់ហ្នឹងមក?
ខៈអើយដល់តែពេលបែកគ្រាប់ផ្លោងហើយអីហ្នឹងមកហើយគេអ៊ីចឹងមកបាន ពួកគេហៅស្អីគេខ្មែរក្រហមគេថាខ្មែរក្រហម។
កៈ ហ៊ឺៗ!!
ខៈ
ចូលមករំដោះចូលមករំដោះអោយយើងចេញៗពីផ្ទះកុំអោយយើងយកអីអោយ សោះទៅ
តែមួយចង្កេះបានហើយ ហើយដល់ពេលទៅយើងដើរទៅតាមផ្លូវរកអីផ្លាស់គ្នា។
(មិត្តភក្តិគាត់)៖ វាបោកយើង។
ខៈ ហ្នឹង!ហើយចុះយើងកេរ្តិ៍អាករយើងក្នុងផ្ទះដែលយើងចេញទៅហើយនោះ។
កៈ គេភូតថាមកវិញទេអី៎?
ខៈ គេថាអោយយើងចេញទៅមួយរយៈសិនទៅ គេថាគ្រាប់ផ្លោងថាអញ្ចឹង។
កៈ វាបោកទៀត?
ខៈ ហ្នឹង។
កៈ
អ៊ីចឹងបើសិនជាអត់បោកថាគ្រាប់ផ្លោងហ្នឹងប្រហែលជាមួយៗអត់ចេញទេអី៎ណោះ
?
ខៈ
ចា៎ដល់តែពេលគេមកដល់ច្រើនពេកយើងពួនក៏គេហៅចេញមកដែរតែមិនចេញ មកទេ
គេបាញ់ចោល។
កៈ អ៊ីចឹងទៀត?
ខៈ ចា៎!!
កៈ គំរាមទៀត?
ខៈ ហ្នឹង!!ចា៎!!
កៈ អី៎ពេលហ្នឹងនៅតាខ្មៅអី៎ហេ?
ខៈ នៅតាខ្មៅ។
កៈ ពេលហ្នឹងនៅផ្ទះយើងមានអីទាំងអស់ហេ?

ខៈ
នៅផ្ទះយើងនៅនេះទៅរត់ទៅតាខ្មៅផ្ទះចិនហ៎ា!!ទៅផ្ទះចិនចិណគេបិតទ្វារបិតអីជិត!!អ៊ី
ចឹងទៅយើងចូលជ្រកជាមួយគេទៅណាស់!!ដល់ទៅគេហៅចេញមក។
កៈ គឺគេដឹងម៉េងអីណោះ?
ខៈ
ហ្នឹងហើយគេហៅចេញមកអោយលើកដៃយើងចេញមកយើងលើកដៃអ៊ុំចឹងមកយើង
ទៅទៅគេអោយទៅផ្លូវណាយើងទៅផ្លូវហ្នឹងទៅ។
កៈ គឺអត់យកអីបានទៅទាំងអស់។
ខៈ គឺអត់មានបានយកអីទៅទេ។
កៈ បើយកទៅអត់បានទៀត។
ខៈ យកទៅវាម៉េចកើត!!បើគេដេញអីទៅលឿនៗហ្នឹង។
កៈ ហ៊ុំអ៊ុំចឹងអត់បានត្រៀមអីទាំងអស់។
ខៈ អត់បានត្រៀមអីទាំងអស់ ទៅតែមួយចង្កេះហ្នឹងម៉ង!!!
កៈ ហ៊ី!!ហើយអ្នកខ្លះស្លៀកតែខោខ្លីអត់មានអាវផងដើរទៅដែរ?
ខៈ ហ្នឹងហើយ ទៅ!!
កៈ ហើយអីដើរទៅដំបូង ទៅផ្លូវដើរទៅណាវិញដំបូង?
ខៈ នេះទៅផ្លូវស្វាយរលំទៅអីនេះដំបូង។
កៈ អត់ដឹងទៅណាចេះតែទៅសិនទៅ?
ខៈ ហ្នឹងហើយចេះតែទៅសិនទៅ។
កៈ អូយរបស់របរនៅផ្ទះ។
ខៈ សុទ្ធតែកាំភ្លើងភ្លង ហ្នឹងហើយ សាញ៉ូអោយទៅណាគឺទៅហ្នឹងទៅ។
កៈ បើមិនទៅបាញ់?
ខៈ ហ្នឹង។
កៈ ចំអាក្រក់ម្លេះអីណោះ?
ខៈ ហ្នឹង!!
(មិត្តភក្តិគាត់)៖ ខ្មែរក្រហមងអាហ្នឹង!!
ខៈ ខ្មែរក្រហមវេទនាណាស់។
(មិត្តភក្តិគាត់)៖ អាខ្មែរខ្មែរខ្មែរក្រហមហ្នឹងសម្លាប់សាហាវណាស់!!
កៈ ហើយអីពេលហ្នឹងស្រណោះទេអី ស្រណោះផ្ទះស្រណោះដី?
ខៈ ស្រណោះផ្ទះស្រណោះសម្បែងដែរហ្នឹង។
កៈ
អីពេលហ្នឹងស្រលាញ់អីគេជាងគេដែរយកទៅស្តាយអត់ព្រមយកទៅបានអ៊ុំចឹងហ៎ា??
អីមានស្រលាញ់អីគេជាងគេនៅក្នុងផ្ទះ?
ខៈ ស្តាយសំពត់អាវអីមួយកំនរ របស់យើង ទូ តុអីមានមួយចប់ហ្នឹង!!
(មិត្តភក្តិគាត់)៖ ហើយតាំងពីនៅក្មេងស្អាតតើ!!
កៈ ហេ!! ដល់ពេលចាស់ទៅគេយកទៅវិញខ្លះហើយអីណោះ?ម្នាក់ម្តង។
ខៈ គេយកទៅអស់ហើយ។
កៈ អើយជីវិតនៅលើផែនដីខ្លីណាស់អីណោះ?
អីដូចមួយពព្រិចភ្នែកអ៊ុំចឹងអីណោះ?
ខៈ ហ្នឹង។
កៈ អ៊ុំចឹងអីដល់ពេលដើរតាមផ្លូវស្វាយរលំហើយធ្លាក់ទៅដល់ណាទៅអី?
ខៈ ធ្លាក់ទៅដល់ស្អីគេ!!ស្ពានព្រែកតូច!!
កៈ ស្ពាន!! ហើយដល់ពេលហើយពីស្ពានព្រែកតូចទៅដល់ណាទៀត?
ខៈ ពោធិ៍សាត់។

ក៖ បានទៅនៅពោធិ៍សាត់ហ្នឹង៣ឆ្នាំ៨ខែហ្នឹងម៉ង?
ខ៖
ចាំ!!បានមកវិញពេលនេះរំដោះបានហ្នឹងភ្នំពេញហ្នឹងមកវិញញុំមចូលនៅព្រៃកហូរ
ហ្នឹងម៉ង ព្រោះពួកក់ញុំមនៅហ្នឹងហ៎ា!!
ក៖ ហ្នំ!!
ខ៖ ពួញុំមគាត់ថាអោយនៅហ្នឹងតែម្តងទៅព្រោះថាទៅស្រុកក៏អស់ផ្ទះដែរ។
ក៖ ហ៊ុំៗ!
ខ៖
គេរូសអស់ដែរផ្ទះពីរខ្ទងគេរូសចេញអស់ទៅពួញុំមទៅសុំគេមួយខ្ទងទុកគេភ្លងកាំ
ភ្លើងពួ
ញុំមត្រូចៀកទៀត!!រកបាញ់ពួញុំមចោល។
ក៖ ចា៎!!
ខ៖ពួញុំមសុំថាសុំរូសតែមួយខ្ទងបានហើយទុកមួយខ្ទងលោរពួកញុំមទៅនៅផង
គេអត់ព្រមទេ។
ក៖ គេរូសយកធ្វើអីគេ?
ខ៖ មិនដឹងគេរូសយកធ្វើអីហ្នំ!!!អស់រលីងផ្ទះពីរខ្ទងសសរប៉ុនៗនេះ។
ក៖ ពេលហ្នឹងអ្នកមានផ្ទះអ៊ីចឹងៗសុទ្ធអ្នកមានអីអ៊ីចឹងហើយអីណេស?
ខ៖ ចាំ!!
ក៖អ៊ីចឹងសំរាប់អីពេលទៅដល់ពេលចូលដល់ក្នុងពោធិ៍សាត់ហ្នឹងដូចរបៀបថាបាន
អីគេហូប ដែរ?
ខ៖ទៅគេមុនដំបូងគេអោយអង្ករអោយអីអញ្ចឹងដាំបាយតែបើយើងមានមាន់មា
នអីយកទៅគេដកយកអស់ហើយ។
ក៖ វាអត់អោយអីជាប់ម៉ងហេ?
ខ៖ហ្នឹងហើយវាដកយកមាន់ហ្នឹងអីគេវាយកដាក់សមូហភាពហ្នឹងអ៊ីចឹងយើងមាន
មាន់មួយ
ពីរគេអោយពីនេះទៅហ្នឹងយកអោយគេនៅណោះដដែលហ្នឹង។
ក៖ អ៊ីចឹងវាថាអោយត្រូវតែធ្វើអីអោយស្មើគ្នាតែម្តងហ្នឹង!!អីណោះ?
ខ៖
ហ្នឹង!ដល់ពេលមុននឹងអោយអង្ករបានប៉ុន្មានថ្ងៃបានហូបបាយរួមហូបបាយរួម
គេធ្វើ
បាយនៅនឹងខ្ទះគេនេះអ៊ីចឹងទៅដល់ពេលគេគោះអាគាំងទៅយើងទៅទៅ។
ក៖ ចាំ!!
ខ៖ ដួសបានមួយបន្តិចម្នាក់មួយបន្តិចម្នាក់ហ្នឹងហូបទៅ!!!
ក៖ ហ៊ុំៗ!!
ខ៖ ហើយវាស្រែកសួរយើងថាឆ្អែតទេបងប្អូន ហើយយើងហ៊ានអត់ថាឆ្អែត។
ក៖ ហើយមួយៗនិយាយថាឆ្អែតទៅ?
ខ៖ ចាំ!!សួរថាឆ្ងាញ់ទេ ?ឆ្ងាញ់។ ឆ្អែតទេ?ឆ្អែត។
ក៖ វាដឹងដែរសោះហ្នឹងអីតែវាធ្វើពើសួរហ៎ាអីហ៎ា!!
ខ៖ ហើយបើថាកាលណាវាសួរថាយើងអត់ឆ្អែតទេ វាយកយើងទៅវ៉ៃចោល។
ក៖ ហ៊ីចេះតែមានម៉ងពុកអាអស់ហ្នឹង ឆ្កួតម៉ងហ៎ា!!
ខ៖ ហើយយើងខំធ្វើចង់ដាប់ស្រូវអង្ករហ៎ា!!
ក៖ ពេលហ្នឹងវាដឹងជញ្ជូនទៅណា?
ខ៖ មិនដឹងជាដឹងជញ្ជូនទៅណា!!
ក៖ អត់ដឹងម៉ងហេពេលហ្នឹង?
ខ៖ អត់ដឹង។
ក៖ ហើយមានដែលមានអ្នកណាគេតវ៉ាទេអី?
ខ៖ អត់មានហ៊ានអ្នកណាគេតវ៉ាទេ។

កៈ តែហ៊ានតវ៉ាចេតរូយ!!
ខៈចាំ!!ធ្វើស្រូវហើយអ៊ីហើយបានតែពីរបីថ្ងៃហើយដឹកហើយអីហើយដឹកអស់រលីងបបរដដែល។
កៈ បាយបានតែប៉ុន្មានថ្ងៃទេហេ?
ខៈ ហ្នឹងហើយបានតែប៉ុន្មានថ្ងៃពេលកំពុងច្រូតកំពុងអីហ្នឹង!
កៈ វាបង្អត់យើងអោយងាប់ម៉ងហា!!
ខៈ អោយងាប់ម៉ងហ៎ា!!
កៈ
មិនដឹងគោលបំនងអីចុះអ៊ីគិតមើលដូចជាខ្មែរសោះហ្នឹងដូចជាអស់ប្រជាជនទៅបានអី
គេបានអ្នកណាអ្នកនៅជាមួយពួកវាទៅ ហើយដល់ពេលបាយរួមទៅ
យូរៗអ៊ីចឹងបិតរោងបាយ បិតរោងបាយតែទឹកបបរអត់ផងបិតរោងបាយបីខែ។
កៈ ហើយចុះហូបអីគេ?
ខៈ ដើររកក្តាមរកខ្យងហូបទៅ!!ពេលណាជួបវាវាវ៉ៃយើងងាប់ភ្លីស្រែទៀត។
កៈ អ៊ីហ៊ីហើយអ៊ីចឹងបម្រុងម៉េចទៅអ៊ីចឹង??អាក្រក់ម្ល៉េះ!!
ខៈ បើយើងដើរអ៊ីចឹងទៅយើងពួនៗទៅកុំអោយវាឃើញ !!
កៈ ហ៊ឺៗ!!
ខៈ រកបានមកហ្នឹងក៏មិនហ៊ានធ្វើអោយហ៊ុយផ្សែងទៀតធ្វើ។
កៈ តែឃើញវា!!
ខៈ ចាំ តែឃើញវាយកយើងវ៉ៃចោល!!
កៈ អ៊ីមួយភូមិហ្នឹងពួកអាទាហានពួកអាឆ្លបហ្នឹងច្រើនទេ?
ខៈ ហ្នឹងហើយ ឆ្លបទូចៗ!!!ប៉ុនៗហ្នឹងឆ្លប។
កៈ មិនព្រមវ៉ៃវិញទៅអត់?
ខៈ វ៉ៃស្អី ធ្វើអីកើត។
កៈ ម៉េចអត់កើតថី?
ខៈ យើងវ៉ៃគេយើងរត់ទៅផ្លូវណារួច?
កៈ វាមានកាំភ្លើង?
ខៈ ហ្នឹង ហើយនៅក្នុងស្រុកហ្នឹងគេកាន់កាប់។
កៈ គឺគេក្តាប់ជាប់ម៉ងហេ?
ខៈ ហ្នឹងហើយ។
កៈ អ៊ីពេលហ្នឹងប្រជាជនហើយនឹងទាហានមួយណាច្រើនជាងពេលហ្នឹង?
ខៈអើរដូចថាកងទ័ពគេដូចវាមានតិចដែរទេហើយប្រជាជនដូចមានច្រើនដែរ
តែអានេះដូចគេក្តោបអត់អោយយើងក្អករួចតែម្តង
គេហៅថាជាប់គុកអត់ជញ្ជាំងហ្នំ!!
កៈ ហ៊ឺៗ!!
ខៈ មានផ្លូវអត់មនុស្សដើរមានជណ្តើរអត់មនុស្សឡើង
មានផ្ទះអត់មនុស្សនៅហ្នឹងហ៎ា!!
កៈ អ៊ីអើយអ៊ី ហើយម៉េចដែរអ៊ីដល់ពេលអញ្ជឹងទៅអារម្មណ៍ហ្នឹងម៉េចដែរ?
ខៈ
អារម្មណ៍គិតថាចុះអញអើយធ្លាប់នៅផ្ទះនៅស្រុកនៅភូមិរកស៊ីបានស៊ីមិនចេះអត់មិនចេះ
អីហើយដល់មកទីនេះអត់មានបាយអត់មានទឹកមួយថ្ងៃមួយថ្ងៃម្ទេតៗៗបញ្ចុក
អោយធ្វើការសំរុកខំហ៎ាបងប្អូនខំសំរុកដល់ពេលញ៉ាំមអត់ញ៉ាំមពេកញ៉ាំមតវ៉ាដែរខំ
សំរុកខំសំរុកសំរុកដូចគេអ្នកធ្វើមើលបីបលានអណ្តាតឥឡូវ!!
កៈ ដល់ហើយវាថាម៉េចទៅ?
ខៈ ដល់ហើយវាយកញ៉ាំមទៅកសាង។
កៈ យកទៅដែរ?

ខ៖ ហ្នឹង។
ក៖ ហើយដល់យកទៅម៉េចទៅ?
ខ៖
សួរញ៉ុមថាមិត្តនារីឯងម៉េចក៏ថាអោយគេ?ញ៉ុមថាហ៊ីញ៉ុមហត់ពេកគាត់អង្គុយលើភ្លឺគាត
ស្រែក ដល់គាត់ស្រែកក៏ញ៉ុមភ្លយមាត់មួយមាត់ទៅ
ញ៉ុមថាបើខំដូចគេតិចធ្លាក់អណ្តាត!!
ក៖ ហើយភ័យទេអីពេលនិយាយហើយ?
ខ៖
វាដល់ពេលញ៉ុមនិយាយជាមួយមេកងមេអីអីហើយអ៊ីចឹងទៅគាត់អោយមកវិញមិត្តនារី
ឯងថ្ងៃក្រោយកុំមាត់កុំករគេថាអីក៏ដោយ។
ក៖ ប៉ះពាល់អីបន្តិចបន្តួចអត់បានម៉ងអីណោះ?
ខ៖ ហ្នឹងហើយ ។
ក៖ ហ៊ុអីក៏លោកឯងអីក៏ម្លេះៗលោក!!
ខ៖ ដល់ពេលថ្ងៃក្រោយឡើងគេឃើញញ៉ុមកំពុងស្ទូងអញ្ចឹងគេថា មិត្តនារីតាំងនេះមើលឆ្អឹងហ៎
លើកអាឆ្អឹងហ្នឹងបង្ហាញញ៉ុមទៀតញ៉ុមថាញ៉ុមឃើញតើឆ្អឹងញ៉ុមឃើញតើថីពូ?ហ្នឹង
ហើយឆ្អឹងសំរាប់ញ៉ុមរើចោលហ៎!!ហ៊ុញ៉ុមថាញ៉ុមមានដឹងណាពូឯងអ្នកនិយាយតើ!!
ក៖ ហើយអ៊ីចឹងម៉េចទៅវាខឹងទេ?
ខ៖
ហើយដល់ហើយទៅគាត់ក៏អត់មាត់ដែរ!!ហ៊ុដល់ពេលថ្ងៃក្រោយឡើងញ៉ុមឈរគោង
សំយ៉ាប់អញ្ចឹងឈរគោងអញ្ចឹងមកដើរមកមិត្តនារីតាំង?ចាំ!!
នេះដាវនេះខ្នងមិត្តនារីតាំងឯងល្មម។
ក៖ និយាយគំរាមអញ្ចឹងម៉ង?
ខ៖ ហ្នឹង។
ក៖ ដល់ហើយម៉េចទៀតទៅអី?
ខ៖ ដល់ហើយញ៉ុមថាដឹងស្អីទេពូ
ដាវឯណាល្មមខ្នងញ៉ុមខ្នងញ៉ុមប៉ុណ្ណណីខ្នងញ៉ុមទូចមួយ!!
ក៖ ហ៊ុតទៀត!!ហើយគាត់មានបានយកទៅគំរាមអីទៀតទេ?
ខ៖
អត់អីទេដល់ពេលថ្ងៃក្រោយដឹងចិត្តញ៉ុមថ្ងៃក្រោយមករើចបមុតៗទុកអោយទុក
អោយញ៉ុមធ្វើការ។
ក៖ ចាំ!!
ខ៖ ថាញ៉ុមធ្វើការសកម្ម អញ្ចឹងរកចបមុតៗទុកអោយមិត្តនារីតាំង។
ក៖ ហ្ហ៎អញ្ចឹងបែរជាស្រលាញ់អីអញ្ចឹងវិញទៅ?
ខ៖ ហ្នឹង។
ក៖ តែពេលមុនគំរាមសម្លាប់គេសោះហ្នឹង?
ខ៖ ហ្នឹង។
ក៖ ពួកគាត់អ្នកមកពីណាវិញបានអាក្រក់ៗម្លេះ?
ខ៖ គាត់នៅស្រុកពោធិ៍សាត់ហ្នឹងម៉ង។
ក៖ ភាគច្រើនគេសុទ្ធតែហៅអ្នកមូលដ្ឋានហ្នឹងអីហេ?
ខ៖ ចាំ!!
ក៖
អ៊ីចឹងអីអីមានដែលធ្លាប់ឃើញអ្នកណាគេយកមនុស្សទៅសម្លាប់ចោលដោយផ្ទាល់ភ្នែក
អីទេ?

ខ៖ ញ៉ុមឃើញដែរ ប៉ុន្តែអត់ហ៊ានមាត់។
ក៖ មើលអីនិយាយមើលថាម៉េចទៅ?ដោយសារតែគេលួវវាលែងអីហើយ!!
ខ៖
ខ្ញុំទៅបត់ជើងប៉ុន្មាននាក់កំពុងតែរែកដីអញ្ចឹងក៏ឈឺបត់ជើងមិនទៅបត់ជើងមានតែទៅ
ក្នុងព្រៃដល់តែទៅក្នុងព្រៃមុនដំបូងដើរទៅពួស្លឹកឈើហើយណាស់ដល់តែឮសូរបាំងអូយ!!បាំងអូយអត់ហ៊ានអោយពួស្លឹកឈើទេលូនមកវិញមកដល់កន្លែងធ្វើការអ្នកណាសួរក៏អត់
មាត់ដែរ!!
ក៖ គេថាដាំដើមគរហ្នឹងអីហេ?
ខ៖ ចាំ!!អ្នកណាសួរថី ស្អែកឯ អាម៉េចក៏អត់នេះដែរអត់និយាយ!!
ក៖ អីឃើញពេលគេវៃហ្នឹងដែរអីហេ?
ខ៖ ចាំ!!
ក៖ អីលួចមើលតាមប្រឡោះទៅ?
ខ៖ លួចមើលតាមប្រឡោះមែកឈើ!!
ក៖ អើយអីអើយអី!!
ខ៖ ហើយដល់អ៊ីចឹងទៅយើងឡើងញាក់អ៊ីចឹងហី!!
ក៖ ដាក់នឹងអីគេ វៃនឹងអីគេ?
ខ៖ ដាក់នេះដាក់នឹងគល់ឫស្សី ។
ក៖ ចំ!!
ខ៖ កញ្ចឹងករ វៃទំលាក់រណ្តៅវៃទំលាក់រណ្តៅ ។
ក៖ ឃើញច្រើនទេអី?
ខ៖
ហ៊ីតែទៅម្តងៗមិនបាច់មិនដែលនេះទេរណ្តៅមួយៗមីអូនអើយអោយសុទ្ធតែខ្មោចតិច
ថាស្រែកទឹកទៅរកទឹកផឹកចុះ ចូលទៅរុយអ៊ូ!!
ក៖ អូយអីអើយអី !! អ៊ីចឹងឃើញតែម្តងហ្នឹងទេអញ្ចឹង?
ខ៖ ចាំញ៉ុមលែងហ៊ានហើយ។
ក៖ ឃើញឡើងញាក់ម៉ងអីហេ?
ខ៖
ចាំ!!មកដល់កន្លែងវិញអង្គុយញាក់ទៀតពួកហ្នឹងសួរថាវាថី?ថាអត់ឃើញអញញាក់ទេអី?
អត់ដឹងថាដល់ម៉ោងអញញាក់ទេហេ?ថាអញ្ចឹងទៀតប៉ា!!
ក៖ ហើយអីនៅហ្នឹងមានខ្មោចលងខ្មោចអីដល់ពេលស្លាប់ច្រើនពេក?
ខ៖ អត់!!ពេលម្លប់ឈើដែរយើងពេលក្តៅអ៊ីចឹងប៉ា យើងចង់ចូលទៅជ្រក
ចូលទៅរុយរោមអ៊ូ អាទទឹងអញ្ចេះក៏មានអាក្បាលជើងតគ្នាម៉េចចាក់បញ្ច្រាស់
សុទ្ធខ្មោច។
ក៖ អូយឃើញដែរ!!!វាវៃឆ្ងាយៗពីភូមិទេអី?
ខ៖ វាវៃជិតៗផ្ទះអញ្ចឹង ដូចម្លប់ឈើអញ្ចឹងទៅ យកទៅដាក់ចោលទៅអញ្ចឹងទៅ។
ក៖ អូយ!!ហើយអញ្ចឹងមួយៗមិនខ្លាចងាប់ហើយ ហើយអីមួយៗមានដឹងអត់?
ខ៖ អើយដឹងក៏មិនដឹងធ្វើម៉េចដែរ។
ក៖ អូយ!!
ខ៖ ចេះតែទៅហើយ។
ក៖ ពេលហ្នឹងលែងមានខ្លាចខ្មោចអីអស់ហើយអី?
ខ៖ លែងខ្លាចអស់ហើយ។បើដើរទៅស្លួងអីវ៉ានជួនកាលឃើញនៅលើភ្លឺស្រែ ។
ក៖ ហ៊ីៗ!!ហើមស្តឹងៗអីទៅ??
ខ៖ ហ្នឹងនៅច្រងាងទៅ!!អាដៃដាក់លើភ្លឺអញ្ចូក ។

កៈ របៀបវា ញុំមឆ្ងល់ថៃបានវាអត់ព្រមយកទៅសម្លាប់អោយឆ្ងាយៗ??
ខៈ ញុំមឆ្ងល់បែបអាករម៉ង!! នេះឃើញក្រវង់អានេះ!!
កៈ ញុំមឆ្ងល់តែវាលើកដៃសម្លាប់ទៅរួចហ៎!!អ៊ីណាស់!!
ខៈ
ហ្នឹងហើយដល់ពេលឃើញអ៊ុំចឹងម្នាក់ៗញាក់មិនហ៊ាននិយាយទេយើងធ្វើអត់ដឹង
ធ្វើអត់
ឃើញធ្វើអត់ឮ!!
កៈ ហើយអញ្ចឹងអ៊ីពេលហ្នឹងចេះតែទៅធ្វើការរាល់ថ្ងៃអីវ៉ាន់អញ្ចឹងទៅ?
ខៈ ចំាចេះតែទៅធ្វើអញ្ចឹងទៅ!!
កៈ
ហើយមានដែលគិតថាមានថ្ងៃណាមួយគេនឹងយកទៅសម្លាប់ចោលអ៊ុំចឹងដែរទេ?
ខៈអារម្មណ៍ចេះតែនឹកឃើញដែរប៉ុន្តែថាគិតគិតទៅថាធ្វើការប៉ុនហ្នឹងហើយ
ងាប់ងាប់ទៅងាប់ថ្ងៃណាចោលថ្ងៃហ្នឹងទៅ។
កៈ ទៅគិតអ៊ុំចឹងវិញទៅហេ?
ខៈ ចំា!!
កៈ បើសិនជាពិបាកពេកក៏វាមិនស្រួលដែរមែនទេ?
ខៈ
ចំា!!ប៉ុនគេម៉េចគេវ៉ៃចោលព្រួសៗចុះយើង??គេខ្លាចអីនឹងវ៉ៃយើងនឹកឃើញទៅអ៊ុំ
ចឹង
វិញទៅ!!
កៈអ៊ីដឹងថាម៉េចទេថាដើម្បីជៀសផុតនឹងការគេសម្លាប់នឹងការគេវ៉ៃហ្នឹងជំនាន់ប៉ុ
ល ពតតើត្រូវធ្វើម៉េច ត្រូវប្រឹងតែខំធ្វើការឬក៏ម៉េចដែរ
ដើម្បីជៀសផុតពីមួយហ្នឹង?
ខៈ
ខំប្រឹងតែធ្វើការមិនមាត់មិននិយាយមិននេះអោយគេតែនិយាយឮគេយកយើង
វ៉ៃចោល
ទៀត។
កៈ ហ៊ឺៗ!!
ខៈ បើរែកដីសុទ្ធតែវាស់ម៉ែត្រដូចថាដាក់ផែនការ៥ម៉ែត្រគីបមួយថ្ងៃ។
កៈ ត្រូវតែធ្វើអោយហើយ?
ខៈ ចំា!
កៈ ចំា!!ហើយចុះឪពុកម្ដាយរបស់អ៊ី
ហ្នំគាត់ស្លាប់មកបែកអាពតនេះមកហើយណោះទេ!
ខៈ ចំា!!
កៈ តែឪពុក!!
ខៈ ឪពុកញុំមស្លាប់នៅអាពត។
កៈ មូលហេតុអីបានគេយកទៅសម្លាប់អ៊ី?
ខៈ គាត់អត់គេសម្លាប់ទេគាត់ស្លាប់នឹងអត់បាយដែរហ្នឹង ហូបមិនឆ្អែតហ្នំ!!
កៈ
ហើយបងប្អូនអ៊ីអ៊ុំចឹងទៅក៏មានអ្នកខ្លះស្លាប់នៅក្នុងហ្នឹងដែរ!!អ៊ីដល់ពេលថ្ងៃដែ
លដឹងថា
បែកពីជំនាន់ប៉ុល ពតមកមួយៗមានអារម្មណ៍ម៉េចដែរ?
ខៈ បែកមកមានអារម្មណ៍សប្បាយរកស៊ីដោយខ្លួនឯងអញ្ចឹងទៅ
បេះត្រកួនអ៊ុំចឹងទៅក៏បេះ
កាប់អុសក៏កាប់អោយតែបានហូបមានអារម្មណ៍ថាសប្បាយរកស៊ីវិញ។
កៈ ដូចរបៀបថាមិនបាច់មានក៏បានដែរអោយតែរួចផុតអ៊ុំចឹងទៅអ៊ីហេ?
ខៈ ចំា!!!ហ្នឹង!!

កៈ លែងចង់មានចង់បានអីអស់ហើយ?
ខៈ ចា៎!!
កៈ ហើយអ៊ីពេលមុនទៅជំនាន់ប៉ុល
ពតហ្នឹងហ៎ាមានមាសមានអីនៅក្នុងគ្រួសារច្រើនអត់?
ខៈ អត់មានទេមានបន្តិចបន្តួច។
កៈ មានតិចតួចតែពួកវាយកពីអ៊ី?
ខៈ ចា៎យកពីញ៉ុមអស់ហើយ មីអូនអើយដាក់ទាំងកញ្ជើរទាំងកញ្ជើរអ៊ីចឹងហិ!!
កៈ មាស?
ខៈ ចា៎!!
កៈ ហើយវាធ្វើមិនដឹងថាហ្នឹងអត់មានតំលៃអីហេ?
ខៈ ហ្នឹងហើយវាដាក់ចោលនៅមួយជួរអ៊ីចឹងហិ!!
កៈ ចំ!!
ខៈ
ខ្ញុំទៅហិហ្នឹងជ្រាវមើលហ៎ា!!ហ៊ីអញយកមួយដៃឥឡូវវី!!នឹកឃើញហ៎ា!!ហ៊ីអញយកមួយដៃ
ឥឡូវវ៉ៃអត់ហ៊ាន ហ៊ីអញយកមួយដៃដាក់ហោរប៉ាវឥឡូវវ៉ៃ!!អត់ហ៊ាន។
កៈ បើយកមួយដៃពេលហ្នឹងអត់អីដែរហី?
ខៈ ហ៊ី!!បើសិនជាយកមកគេឃើញគេវ៉ៃងាប់!!កៈហ៊ីៗ!!ខៈ
អ៊ីចឹងក៏អត់ហ៊ានអីហ្នឹង!!
កៈ ទុកចោលនៅក្នុងណាវិញទៅ?
ខៈ ទុកនៅហ្នឹងវត្ត!!ទុកនៅនឹងវត្តតែមិនដឹងនៅវត្តអីទេ។
កៈ ចា៎!!
ខៈ យកទៅដាក់មុខព្រះអង្គហ្នឹងឡើងដង្ហែរ!!
កៈ ហ៊ីៗ!!
ខៈ
យើងបានតែមើល!!នឹកឃើញថាអញ្ចេកព្រះអង្គសំលឹងមកយើងចុះបើយើងយកទៅ
ព្រះអង្គវ៉ៃបំបាក់ករទៅក៏មិនដឹង ហ្នឹងនឹកឃើញថាអញ្ចឹង
អញ្ចឹងតែបន្តិចអត់ហ៊ានពាល់ផង!!
កៈ ដល់ពេលបែកប៉ុល ពតមកមានអ្នកណាបានមាសបានអីច្រើនទេអ៊ី?
ខៈ ហ៊ីញ៉ុមអត់ដឹងដែរពួកគេអ្នកបាន គេបាន យើងអត់អត់។
កៈ តែអ្នកណាគេបើបានដល់ករម៉ងដែរហ្នឹងហ៎ា!!
ខៈ ហ្នឹង!!
កៈ គ្រប់ទឹកម៉ងអ៊ីណោះ?
ខៈ ចា៎!!
កៈអ៊ីនៅថ្ងៃដែលវៀតណាមចូលមកក្នុងស្រុកវាម៉េចដែរ?ពេលថ្ងៃដឹងដែរបែកប៉ុល
ពតមកម៉េចដែរ?
ខៈ ញ៉ុមអត់បាននៅដល់បែកផងញ៉ុមបែកចេញមក!!
កៈ រត់ទៅនៅឯណាវិញ?
ខៈ ញ៉ុមរត់មកពោធិ៍សាត់មក។
កៈ ចឹបានរត់មកពោធិ៍សាត់វិញអ៊ី?
ខៈ ព្រោះគេដាក់ទោសអោយញ៉ុមមកទួលស្រូវ!!
កៈ ហ្វ៊ូ!!
ខៈ មកជញ្ជូនស្រូវហ៎ា!!
ខៈដល់ពេលញ៉ុមមកអ៊ីចឹងទៅគ្នាមក៣នាក់ជំនុំគ្នាយប់ឡើងយើងនៅក៏ងាប់ដែរ
យើងនៅក៏ងាប់យើងនៅក៏ងាប់ឥឡូវមានតែយើងផ្សងព្រេងទេ!!អ៊ីចឹងក៏នាំគ្នា
ចេញមកទៅគ្នាប៉ុន្មាន១៣នាក់ហ្នឹង។

ក៖ បងប្អូនឬក៏ជាមួយអ្នកផ្សេង?
ខ៖ អ្នកផ្សេង។
ក៖ ហ៊ឺ!!
ខ៖ ញ៉ុមមានតែប្អូនញ៉ុមតែមួយទេ!!ជាមួយម៉ែផល្លាហ្នឹង។
ក៖ ចា៎!!
ខ៖ វានៅតូច។
ក៖ យកមកតាមមក?
ខ៖ ចា៎យកមកតាមខ្លួន។
ក៖ ចុះពេលហ្នឹងម៉េចអ៊ីបានត្រូវរត់អ៊ីចឹង?គេថាម៉េច?
ខ៖ គេអត់ថាទេព្រោះអីជិតបែកហ្នុ៎!!
ក៖ ហ៊ឺៗ!!
ខ៖
ពេលហ្នឹងដូចថាពេលវៀតណាមទៅរំដោះហ្នឹងវាទៅរំដោះហ្នឹងគេជិតរំដោះបានហើយ ញ៉ុមក៏នាំគ្នារត់ចេះទៅ!!ពេលហ្នឹងបើយើងមិនរត់ចេះក៏គេវៃចោលដែរ។
ក៖ ហ៊ឺៗ!!តែដឹងថាវៀតណាមចូលមកហើយអីណេះ?
ខ៖ ដឹង ដល់ដឹងអ៊ីចឹងទៅបាននាំគ្នារត់ចេញមកបានឡើងទៅពោធិ៍សាត់ ។
ក៖ តែពេលហ្នឹងអ៊ីរនៅពោធិ៍សាត់ដដែលតើអីហេ?
ខ៖ ចា៎!!
ក៖ តែរត់ឡើងមកទីរួមខេត្តឬមួយក៏អី?
ខ៖ រត់ពីកន្លែងភូមិនៅហ្នឹងមកមកពោធិ៍សាត់ម៉ង!!
ក៖ តែពេលនៅភូមិនៅហ្នឹងនៅខេត្តពោធិ៍សាត់ហ្នឹងដែរ?
ខ៖ ចា៎!!
ក៖ ឡើងមក?
ខ៖ ដើរមួយយប់ទល់ភ្លឺបានមកដល់ពោធិ៍សាត់ហ្នឹង។
ក៖ ចា៎មកទីរួមខេត្តហ្នឹង?
ខ៖
ចា៎!!មកដល់គេអោយដេកសំរាក១៣ថ្ងៃបានគេរំសាយយើងអោយរកកន្លែងនៅ។
ក៖ អ៊ីចឹងពេលហ្នឹងក៏រួចផុតទៅ?
ខ៖ ចា៎!!
ក៖
អ៊ីចឹងអីពេលដែលបែកប៉ុលពតហ្នឹងមកមានអារម្មណ៍ថាខ្សោកមានអារម្មណ៍ថាធូរអស់
ពេលហ្នឹង?
ខ៖
ពេលហ្នឹងមានអារម្មណ៍ថាអរថាបានមកហើយតែនៅក្នុងស្រុកហ្នឹងទៀតមិនដឹងបានអី
មកស្រុកយើងវិញ !!
ក៖ ទៅពិបាកអ៊ីចឹងទៀត?
ខ៖
ចា៎!!ពិបាកគិតអ៊ីចឹងដល់ពេលប្អូនប្រុសញ៉ុមនោះបានគោមួយណឹមបានគោមួយណឹមក៏
ដូរអង្ករគេគេបានគោមួយបានអង្ករ៣តៅមួយទៀតបានដូរអារ៉ឺម៉ក់ហ្នឹងដូរយកមកហ្នឹងបានបានមកដល់ព្រែកហូរហ្នឹង។
ក៖ អ៊ីចឹងហើយក៏នៅហ្នឹងទៅ?
ខ៖ ចា៎!!
ក៖ អីពេលបែកប៉ុល ពតមកអីប្រកបមុខរបរអីចិញ្ចឹមជីវិតខ្លះទៅ?
ខ៖ ញ៉ុមបេះត្រកួន ញ៉ុមកាប់អុស រាវលៀស ។

ក៖ ចំា!!
ខ៖ បាចត្រី រកមួយចប់។
ក៖ ដល់ពេលអ៊ីចឹងបែកមកបានប៉ុន្មានឆ្នាំបានឡកឆៃយុំទៀត?
ខ៖ នេះបានប៉ុន្មានឆ្នាំបានកូនច្រើនដែរហើយហ្នឹង បានលេង។
ក៖ បានកើតរបរហ្នឹងទៅ?
ខ៖ ចំា!!
ក៖ ហើយគេមកកាន់គ្រូអីអ៊ីចឹងទៅអ៊ីណោះ?
ខ៖ ចំា!!
ក៖ អ៊ីកូនទាំងអស់ទាំងប្តីទាំង៣នាក់ហ្នឹង
កូនសរុបទាំងអស់មានកូនប៉ុន្មាននាក់?
ខ៖ ទាំងអស់មានប៉ុន្មាន !!៨ ៩នាក់។
ក៖ហើយអ៊ីមានកូនហើយចាំឈ្មោះកូនមើលរៀបរាប់ឈ្មោះកូនទាំងអស់មើល
ឈ្មោះអីគេខ្លះ?
ខ៖ អាងាប់ៗហ្នឹងអត់ដាក់ឈ្មោះផង។
ក៖ ដោយសារវារលូតឬក៏ម៉េចអ៊ី?
ខ៖ វាកើតមកងាប់កើតមកងាប់។
ក៖ ហ្ហុំអ៊ីចឹងអត់បានដាក់ឈ្មោះទេអ៊ីចឹង?
ខ៖ ហ្នឹងហើយ។
ក៖ អញ្ចឹងប្រាប់ឈ្មោះអ្នកដែលចាំមើល?
ខ៖ ចំាតែប៉ុន្មាននាក់ហ្នឹង។
ក៖ អ្នកណាគេខ្លះ?
ខ៖ ធឿន គុប ទុំ អាទូរ ចាំនៅតែ៤នាក់ហ្នឹង។
ក៖ ឥឡូវពួកគាត់នៅឯណាវិញ?
ខ៖ អាពៅហ្នឹងវាទៅធ្វើការ!!
ក៖ ស្រីទុំហ្នឹងទៅណា?
ខ៖ ទុំទៅនៅជាមួយ!!
ក៖ ប្តី?
ខ៖ ខាងប្តីហ្ហុំ!!
ក៖ តែកូនៗអីវ៉ាន់?
ខ៖ កូនៗនៅខ្ញុំទាំងអស់។
ក៖ តែគាត់មានបានផ្តល់អីអោយកូនអត់?
ខ៖ នៅទេ ទឹមចេញមកពីគុក។
ក៖ ហ្ហុំម៉េចអ៊ីចឹងវិញ?
ខ៖ ជាប់គុកប៉ុន្មានឆ្នាំហើយនឹងទឹមតែចេញមកតើ!!
ក៖ ហ៊ុ!!ទាំងពីរនាក់ប្តីប្រពន្ធឬក៏ម៉េច?
ខ៖ ចំា!!កូនៗតែញ៉ុមចិញ្ចឹមហ្នឹង។
ក៖ មូលហេតុអីបានជាជាប់គុកវិញអ៊ី?
ខ៖ អើយវាជក់ថ្នាំ។
ក៖ ហ្ហុំ!!ហើយមានកូនឡើងលញ៉ុងហើយនៅ!!ហើយអ៊ីម៉េចទៅអ៊ីហើយអ៊ីចឹង??
ខ៖ អ៊ីចឹងបានថាវេទនាវេទនាអាណាវេទនាតែញ៉ុមហ្នឹង។
ក៖ ហ៊ឹៗ!!
ខ៖ មើលចិញ្ចឹមចៅឡើងងងឹតភ្នែកងងឹតអីអស់ហើយហ្នឹង។
ក៖ ហើយឥឡូវហ្នឹងអ្នកណាគេទៅជាអ្នកផ្តល់លុយផ្គត់ផ្គង់ទៅ?
ខ៖ ឥឡូវកូនៗញ៉ុមធ្វើនេះនៅយេស៊ូវដែរហ្នឹងហ៎ា!
ក៖ ចំា!!

ខៈ វាចេះតែអោយ៤០០០០ ៥០០០០ទៅ
មីប្អូនញុំមមិនៅជាមួយគេនោះវាអោយមក ៤០០០០
៥០០០០អីអ៊ុចឹងមកគេភ្ជួបគេគ្នាទៅគេអោយយកមកទៅ!!
កៈ ចា៎!!
ខៈ អ៊ុចឹងយើងទិញហូបទៅ។
កៈ ចា៎!!ជួយគ្នាបន្តិចបន្តួចទៅ?
ខៈ ចា៎!!
កៈ ហូបបន្ទាប់បន្សំអ៊ុចឹងទៅអីណោះ?
ខៈ ចា៎តាគាត់អោយមកខ្លះអ៊ុចឹងទៅ!!
កៈ ហ្ន៎!!
ខៈ
ហើយជួនកាលញុំមអីទៅរកអីបានអ៊ុចឹងទៅចេះតែផ្សំៗអ៊ុចឹងទៅបានមកវាចេញមកហ្នឹង។
កៈ ចា៎ហ្នឹងហើយ។
ខៈ ឥឡូវទៅវិញទៀត។
កៈ
ចា៎!អ៊ុចឹងអីសំរាប់កូនចៅទាំងអស់ហ៎ា!!អីមានអោយពួកគាត់មានបានទៅរៀនខ្លះអត់?
ខៈ បានទៅរៀនតែមីស្រីទុំមួយទេហើយនឹងអាពៅ។
កៈ ចា៎ ពេលហ្នឹងគាត់បានរៀនច្រើនដែរតើអីហេ?
ខៈ ស្រីទុំរៀនបានថ្នាក់ទី៥។
កៈ ញុំមដូចធ្លាប់រៀនជាមួយស្រីទុំដែរហេ!!ញុំមមានអារម្មណ៍ថាអញ្ចឹង។
ខៈ ថ្នាក់ទី៥។
កៈពេលហ្នឹងស្រីទុំខូចហេ!!!រៀននៅជាមួយគ្នាមិនមែនខូចអីទេរបៀបថាលេងជាមួយគ្នា ប្រណែនលេងអីអញ្ចឹងទៅណាស់!!ធម្មតាក្មេងហ្ន៎អី!!
ខៈ ចេះតែឈ្លោះគ្នា។
កៈ
ចា៎ហ្នឹងហើយឈ្លោះក៏មិនអីណាស់ណាដែរទេ!!គ្រាន់តែប្រណែនគ្នាលេងថាលេងជាមួយអានេះច្រើនជាងអានោះច្រើនជាងហ្នឹង!!
ខៈ ហ្នឹងហើយ។
កៈ ប្រហែលអ៊ុចឹង តាមញុំមចាំ។ចា៎ អ៊ុចឹងអីសំរាប់សព្វថ្ងៃអ៊ីប្រកបរបរអីគេដែរ?
ខៈ
ញុំមរាល់ថ្ងៃមើលចៅនៅតែផ្ទះហ្នឹងបានគេអោយតិចៗអ៊ុចឹងមកចេះតែហូបតិចៗទៅ។
កៈ ចា៎!!
ខៈ ចិញ្ចឹមចៅអ៊ុចឹងទៅ។
កៈ ហ្នឹងហើយ។
ខៈ
តាមរកនោះអត់មានទេបើពេលគេជួលអ៊ុចឹងទៅបានទៅលេងអ៊ុចឹងទៅម្តងម្កាលអ៊ុចឹង
ទៅ។
កៈ ចា៎!!អីចូលចិត្តហូបម្ហូបអីគេដែរអី?
ខៈ ញុំមហេ?
កៈ ចា៎!!
ខៈ ហ៊ុញុំមម្ហូបញុំមឥឡូវៗនេះហូបអីក៏ហូបអត់កើតដែរ។។
កៈ ម៉េចអ៊ុចឹងវិញ?
ខៈ អញ្ចឹងទៅញុំមចំហុយតែប្រហុកលិតមួយពេលតិចៗហ្នឹង!!

កៈ អ៊ីចឹងម៉េចមានកំលាំងកំហែងអ៊ី?
ខៈ អ៊ីចឹងបានស្គមទៅស្គមទៅហ្នឹងមើល!!
កៈ
មើលហូបអីខ្លះទៅទោះអត់ឆ្ងាញ់ប្រឹងហូបហ្ន៎ដោយសារអ៊ីអាហ្នឹងចិត្តប៉ុន្តែអារូបរាង
កាយ
ហ្នឹងវាត្រូវការការពារ ដល់អ៊ីចឹងពិបាកវិញទេអ៊ីឈីហ៎ា!!
ខៈ ចា៎!!
កៈអ៊ី អ៊ីឯងខំប្រឹងហូបវិញដើម្បីចៅអីវ៉ាន់មើលអានិតពួកវា
ពួកវាអត់ទាន់ធំផង។ ចៅៗហ្នឹងហ៎ា
មើលយាយផងមើលកុំធ្វើបាបយាយពេកស្តាប់យាយផងយាយខំរកស៊ីខំមើលថែអ៊ី
ចឹងហ៎ា!!អានិតយាយហើយមានអីហូបអីវ៉ាន់ឆ្ងាញ់ៗអោយយាយហូបផង(និយាយ
ប្រាប់ចៅគាត់)អ៊ីអ្វីដែលសង្ឃឹមទៅថ្ងៃក្រោយសង្ឃឹមអីគេទៅអ៊ី?
ខៈ រាល់ថ្ងៃមិនដឹងសង្ឃឹមអីទេចាស់ទៅ!!
កៈ ហ៊ុៗ!!
ខៈ ពេលឥឡូវហ្នឹងមិនដឹងសង្ឃឹមអីផងទេនេះ!!
កៈ តែគ្រាន់តែអ៊ីបានមានកូនច្រើនអីវ៉ាន់ដែរអ៊ីណោះ?កូនចៅអីវ៉ាន់អ៊ីចឹងដែរ!!
ខៈ ចា៎ !! បានច្រើនតែមិនដឹងរកអីកើតប៉ុនៗហ្នឹងហិ!!
កៈតែបន្តិចទៀតហ្នឹងហ៎ា!!អ៊ីឯងចាំមើលតែភ្លេចច្រចៀកហ្នឹងហ៎ា!!ធំលឿនដូចរ
ន្ទះអ៊ីចឹង។
ហើយកុំជក់ម៉ាជក់អីលីអត់?ហើយខំប្រឹងរកការងារធ្វើដោយសារឃើញគំរូរបស់មីង
ទុំមួយហើយឡើងជាប់គុកអីវ៉ាន់ហ្ន៎!!កុំធ្វើមួយហ្នឹងពាក្យថាគុកមួយម៉ាត់វាអត់ស
ប្បាយទេគុកមួយម៉ាត់គឺអត់ទៅណារួចទេ!!
ខៈ ចា៎!!
កៈ ដូចថាគិតមើលមើល អ៊ីអត់ជញ្ជាំងអ៊ីចឹងទៅណាក៏ពិបាកដែរមែនទេ?
ខៈ ហ្នឹង។
កៈ ចុះទំរាំតែអាមានជញ្ជាំងទៀត!!
ខៈ ចុះទំរាំតែមានជញ្ជាំងទៀត!!
កៈ វាពិបាកវេទនាប៉ុណ្ណាទៅអ៊ីណោះ??
ខៈ ចា៎បាយក៏ហូបមិនឆ្អែត។
កៈ
ចា៎ហ្នឹងហើយអ៊ីចឹងអ៊ីបងប្អូនរបស់អ៊ីទាំងអស់គឺមានតែអ៊ីទេដែលចេះលេងឧបក
រណ៍
តន្ត្រីលេងឆៃយ៉ាំហ្នឹងហេ??
ខៈ ចា៎!!
កៈ លេងឃីកេអីហ្នឹង!!មានបងប្អូនណាចេះលេងអីផ្សេងទៀតទេ??
ខៈ អត់!!មានកូនពៅញ៉ុមមួយចេះលេងភ្លេងសៀមចេះលេងនៅវត្តហ្នឹង។
កៈ ឥឡូវហ្នឹងហេ?
ខៈ ឥឡូវឈប់អស់ហើយបែកគ្នាអស់ហើយហើយហ្នឹង!!
កៈ ហ្ន៎!!
ខៈ កាលហ្នឹងវានៅរៀនលេងហ្នឹង!!
កៈ ចា៎!!
ខៈ តែមិនត្រឹមតែរៀនទេ គេជួលទៅលេងបានមួយកំនរដែរហ្នឹង!!
កៈ ចា៎!!ឥឡូវទៅណាទៅ?
ខៈ ឥឡូវវាបែកបាក់គ្នាអស់ហើយអ្នកលេងអ្នកអីហ្នឹង!!
កៈ ហ្ន៎!!អ៊ីចឹងឥឡូវទៅធ្វើការទៅអីអញ្ចឹងទៅ?
ខៈ ចា៎!!ហើយភ្លេងសៀមនៅហ្នឹងវត្តហ្នឹងមិនដឹងទៅណាមកណាទៀតផង!!
កៈ ហ្នឹងហើយឥឡូវលេងសូវមានអីអស់ហើយអ៊ីអើយ!!

ខះ វត្តស្វាត់តាំងពីនៃឃុំញ៉ុមក៏ដោយឃើញទេ??ពីដើមញ៉ុមលេងនៅវត្តហ្នឹងហ៎ា!!
កះ ហ្នឹងហើយឃើញរហូត!!
ខះអញ្ចេកបានញ៉ុមអត់លេងបងចាន់ហ្នឹងអើរគាត់ឃើញយើងទៅលេងអ៊ុំចឹង
!!ហ៊ុំបានមកលេងអ៊ុំចឹងអរហើយ!!
កះ ហ៊ុំ!!
ខះ តែថ្ងៃក្រោយចាំគេអញ្ជើញ!!
កះ ហ្ន៎!!
ខះ ញ៉ុមថាបើថ្ងៃក្រោយអញ្ជើញទាល់តែលុយ!!
កះ ចា៎!!
ខះ បើអត់មានអ្នកណាអញ្ជើញទេគឺញ៉ុមអត់ទាររទេលុយ។
កះ ហ៊ុំៗ!!
ខះ ខ្ញុំលេងតាមកំលាំងមិត្តភាពរបស់ញ៉ុមបងប្អូនអោយក៏យកមិនអោយក៏ហឺ!!
កះ ហ៊ុំៗ!!
ខះ ដល់ហើយញ៉ុមឈប់លេងរហូតអ៊ុំចឹងទៅឃើញទេ??
កះ ចា៎!!
ខះ
ឥឡូវលោកថាញោមលេងនៅវត្តមកតាថាគេជគុណកាណាជាប់លេងវត្តឯណោះហើយ!!
រាល់ឆ្នាំ!!
កះ ដល់ពេលមានបុណ្យទានអីវ៉ាន់អ៊ុំចឹងទៅ?
ខះ ចា៎!!
កះ
អ៊ុំចឹងអ៊ីមួយនេះគឺជាសំនួរមួយចុងក្រោយអរគុណសំរាប់ការរៀបរាប់ពីជីវិតដ៏ក្បោះក្បាយ
អ៊ុំចឹងហ៎ា!!អ៊ុំចឹងតើអ៊ីមានពាក្យអីដែលចង់ផ្ដែផ្ដាំទៅកាន់កូនចៅជំនាន់ក្រោយអ្នកដែលអត់ទាន់កើតអីវ៉ាន់ដែលអត់ទាន់ឮសំលេងរបស់អ៊ីហ៎ា!!តើចង់អោយគាត់ដើរលើផ្លូវអីគេដែរ?ផ្លូវម៉េច?
ខះចង់អោយគាត់ដើរលើផ្លូវល្អត្រឹមត្រូវរកស៊ីដោយកំលាំងយើងសមត្ថភាពរបស់យើង កុំលួចប្លន់គេ កុំឆក់បោកគេ មានអីនឹងផ្ដែផ្ដាំទេមានតែប៉ុណ្ណឹងទេ!!
កះ ចុះអោយជៀសផុតពីអីគេដែរអ៊ី?
ខះ ចា៎?
កះ ជៀសផុតពីអីគេដែរ អោយគាត់ជៀសផុតហ៎ា?
ខះ ចា៎ជៀសផុតពីរឿងជក់ថ្នាំជក់អីនេះកុំប្រព្រឹត្ត!!
កះ ហ៊ីៗ!!
ខះ ហ្នឹងយាយនៅរស់យាយចេះតែមើលចុះបើយាយងាប់បាត់ទៅ!!
កះ ចា៎!!នៅម្ដុំនេះគេថាច្រើនណាស់អ៊ីហេ?
ខះ ហ្នឹង!!
កះតែថែរក្សាខ្លួន!!!(និយាយប្រាប់ចៅគាត់)ទូចៗអ៊ុំចឹងហាមើលខ្លួនប្រយ្ឆត័ហិ!!
ចា៎ហ្នឹងហើយអញ្ចឹងអរគុណច្រើនណាស់អ៊ីសំរាប់ការសំភាសន៍ដ៏ក្បោះក្បាយនៅថ្ងៃនេះហើយអ្វីទាំងអស់កូនចៅរបស់អ៊ីកូនចៅអ៊ីនឹងបានស្ដាប់ដល់ពេលថ្ងៃខាងក្រោយទុកជាឯកសារសំរាប់ជីវិតអ៊ីទៅថ្ងៃខាងក្រោយអ៊ុំចឹងហ៎ា!!ថាតើជីវិតអ៊ីឆ្លងកាត់អីគេខ្លះកូនចៅស្ដាប់ទៅណាស់អ៊ីណាស់!!!អ៊ុំចឹងអរគុណអ៊ីណាស់
!!អ៊ុំចឹងអ៊ីចង់មាននិយាយអីថែមទៀត!!
ខះ សូមអំណរអរគុណគាត់មកសំភាសន៍ខ្ញុំ!!
កះ ចា៎!!
ខះ ញ៉ុមសូមអរគុណអោយគាត់បានអាយុព្រះជន្មយឺនយូរ។
កះ ចា៎ហ្នឹងហើយ!!ចា៎!!

ខ៖ ចា៎!!
ក៖ ហ្នឹងហើយគ្រាន់តែជាឯកសារទៅថ្ងៃក្រោយទៅអ៊ីណោះ?
ខ៖ ចា៎!!
ក៖ ចា៎អញ្ចឹងអរគុណច្រើនណាអ៊ី!!
ខ៖ ចា៎៕